# Sendai Framework for Disaster Risk Reduction 2015 - 2030

United Nations

# ក្របខ័ណ្ឌការងារសេនដាយសម្រាប់ការ
# កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ
# ២០១៥ ~ ២០៣០

# ក្របខ័ណ្ឌការងារសេនដាយសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០១៥ ~ ២០៣០

ប្រែសម្រួលដោយ អគ្គលេខាធិការដ្ឋាន គ.ជ.គ.ម.

# អារម្ភកថា

ក្របខ័ណ្ឌការងារសេនដាយ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ឆ្នាំ២០១៥~២០៣០ ត្រូវបានអនុម័ត នៅឯសន្និសីទពិភពលោកលើកទី៣ នៃអង្គការសហប្រជាជាតិនៅទីក្រុងសេនដាយ ប្រទេសជប៉ុន នាថ្ងៃទី១៨ ខែមិនា ឆ្នាំ២០១៥។ ហើយក៏ជាលទ្ធផលនៃកិច្ចពិគ្រោះយោបល់របស់ភាគីពាក់ព័ន្ធ ដែលបានផ្តួចផ្តើមឡើងនាខែមិនា ឆ្នាំ២០១២ និងការចរចារបស់ អន្តររដ្ឋាភិបាល ចាប់ពីខែកក្កដា ឆ្នាំ២០១៤ ដល់ខែមិនា ឆ្នាំ២០១៥ ដោយទទួលបានការគាំទ្រ ពីការិយាល័យសហប្រជាជាតិ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដោយអនុលោមតាមសំណើរបស់មហាសន្និបាតរបស់អង្គការសហប្រជាជាតិ។

ក្របខ័ណ្ឌការងារសេនដាយ គឺជាឧបករណ៍ស្នងជំនួស ក្របខ័ណ្ឌការងារសកម្មភាពយូហ្គោ (HFA) ២០០៥~២០១៥: ការកសាងភាពធន់របស់ជាតិ និងសហគមន៍ទៅនឹងគ្រោះមហន្តរាយ។ ក្របខ័ណ្ឌការងារសកម្មភាពយូហ្គោ នេះត្រូវបានបង្កើតឡើងដើម្បីផ្តល់នូវសន្ទុះ បន្ថែមទៀតដល់ការងារពិភពលោក ក្រោមក្របខ័ណ្ឌការងារសកម្មភាពអន្តរជាតិ នៃទសវត្សរ៍អន្តរជាតិសម្រាប់ការកាត់បន្ថយគ្រោះមហន្តធម្មជាតិ នៃឆ្នាំ១៩៨៩ និងយុទ្ធសាស្រ្តទីក្រុងយ៉ូកូហាម៉ាសម្រាប់សុវត្ថិភាពពិភពលោក: គោលការណ៍ណែនាំសម្រាប់ការត្រៀមបង្ការ ការត្រៀមរៀបចំ និងការកាត់បន្ថយគ្រោះមហន្តរាយធម្មជាតិ និងផែនការសកម្មភាពរបស់ខ្លួន ដែលបានអនុម័តនាឆ្នាំ១៩៩៤ និងយុទ្ធសាស្រ្តអន្តរជាតិសម្រាប់ការកាត់បន្ថយគ្រោះមហន្តរាយនាឆ្នាំ១៩៩៩។

ក្របខ័ណ្ឌការងារសេនដាយ ត្រូវបានបង្កើតឡើងផ្អែកលើធាតុ ដែលធានាដល់និរន្តរភាពនៃការងារដែលបានអនុវត្តដោយរដ្ឋ និងគ្រប់ភាគីអ្នកពាក់ព័ន្ធផ្សេងទៀត នៅក្រោមក្របខ័ណ្ឌការងារសកម្មភាពយូហ្គោ និងបានណែនាំនូវនវកម្ម (ការបង្កើតថ្មី) មួយចំនួន ដូចដែលបានអំពាវនាវនៅ អំឡុងពេល នៃកិច្ចពិគ្រោះយោបល់ និងការចរចា។ អ្នកធ្វើអត្ថាធិប្បាយជាច្រើនបានកំណត់បញ្ជាក់ថាមានការផ្លាស់ប្តូរដ៏សំខាន់បំផុត ដោយសង្កត់ធ្ងន់ខ្លាំងទៅលើការគ្រប់គ្រងគ្រោះ មហន្តរាយ ដែលប្រឈមទៅនឹងការគ្រប់គ្រងគ្រោះមហន្តរាយ និយមន័យនៃគោលដៅជាសកលចំនួនប្រាំពីរគឺ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដែលជាលទ្ធផលរំពឹងទុក គោលបំណងផ្តោតទៅលើការត្រៀមបង្ការហានិភ័យថ្មី ការកាត់បន្ថយហានិភ័យដែលមានស្រាប់ និងការពង្រឹងភាពធន់ក៏ដូចជាការដាក់ចេញនូវគោលការណ៍ណែនាំ រួមបញ្ចូលទាំងការទទួល ខុសត្រូវជាចំបងរបស់រដ្ឋ ដើម្បីបង្ការ និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ នៅទូទាំងស្ថាប័នសង្គម និងរដ្ឋ ដែលពាក់ព័ន្ធ។ លើសពីនេះទៀត ទំហំនៃការកាត់បន្ថយហានិភ័យ

គ្រោះមហន្តរាយ ត្រូវបានពង្រីក និងផ្តោតជាសំខាន់ទៅលើទាំងមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ និងមនុស្ស មុខសញ្ញាគ្រោះថ្នាក់ និងហានិភ័យ បរិស្ថាន បច្ចេកវិទ្យា ជីវសាស្ត្រ ដែលពាក់ព័ន្ធ។ ភាពធន់របស់សុខភាពត្រូវបាន លើកកម្ពស់យ៉ាងខ្លាំងជាទូទៅ។

ក្របខ័ណ្ឌការងារសេនដាយ ក៏ត្រូវបានគាក់តែងដូចតទៅ:តម្រូវការសម្រាប់លើកកម្ពស់ ការយល់ដឹងពីហានិភ័យគ្រោះមហន្តរាយ នៅគ្រប់ជ្រុងជ្រោយនៃកម្រិតរងគ្រោះ ភាពងាយរងគ្រោះ និងលក្ខណៈវិនិច្ឆ័យនៃមុខសញ្ញាគ្រោះថ្នាក់។ ការពង្រឹងអភិបាលកិច្ចហានិភ័យគ្រោះមហន្តរាយ រួមបញ្ចូលទាំងវេទិកាជាតិ។ គណនេយ្យភាពសម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយ ការត្រៀម រៀបចំដើម្បី *"ការស្ថាបនាឲ្យប្រសើរជាងមុន"*។ ការទទួលស្គាល់នៃគ្រប់ភាគីពាក់ព័ន្ធ និងតួនាទីរបស់ពួកគេ។ ការកៀរគរ សម្រាប់ការវិនិយោគលើហានិភ័យឆាប់ភ័យខ្លាច ដើម្បីជៀសវាងនូវ ការ បង្កើតហានិភ័យថ្មី។ ភាពធន់របស់ហេដ្ឋារចនាសម្ព័ន្ធសុខភាព កេរតំណែលវប្បធម៌ និង កន្លែងធ្វើការ។ ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងភាពជាដៃគូសកលគោលនយោបាយ និងកម្មវិធីរបស់ម្ចាស់ជំនួយ រួមទាំងការគាំទ្រផ្នែកហិរញ្ញវត្ថុ និងប្រាក់កម្ចីពីស្ថាប័ន ហិរញ្ញវត្ថុ អន្តរជាតិ។ មានការទទួលស្គាល់យ៉ាងច្បាស់លាស់ផងដែរ ពីវេទិកាសកលសម្រាប់ ការកាត់បន្ថយហានិភ័យ និងវេទិកាថ្នាក់តំបន់សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដែលជាយន្តការសម្រាប់របៀបវារៈពាក់ព័ន្ធទូទៅ ការតាមដានត្រួតពិនិត្យ និងការពិនិត្យតាម កាល កំណត់ ដោយមានការគាំទ្រពីស្ថាប័នអភិបាលកិច្ចសហប្រជាជាតិ។

លេខាធិការដ្ឋាន នៃយុទ្ធសាស្ត្រអន្តរជាតិសម្រាប់ការកាត់បន្ថយគ្រោះហន្តរាយ សហប្រជាជាតិ (UNISDR) បានទទួលភារកិច្ច ដើម្បីគាំទ្រដល់ការអនុវត្ត ការតាមដាន និងការត្រួតពិនិត្យឡើងវិញ នៃក្របខ័ណ្ឌការងារសេនដាយ។

**ម៉ាហ្គារ៉េតា វ៉ុលស្ត្រុំ**
តំណាងពិសេសរបស់អគ្គលេខា អង្គការសហប្រជាជាតិ
ទទួលបន្ទុក ការងារកាត់បន្ថយគ្រោះហន្តរាយ

# មាតិកា


ទំព័រ

| | | |
|---|---|---|
| បុព្វកថា | ........................................................................................ | ៩ |
| គោលបំណង និងលទ្ធផលរំពឹងទុក | .................................................... | ១២ |
| គោលការណ៍នៃការណែនាំ | ................................................................ | ១៣ |
| សកម្មភាពអាទិភាព | ........................................................................ | ១៤ |
| អាទិភាពទី១ : ការយល់ដឹងអំពីហានិភ័យគ្រោះមហន្តរាយ | ................. | ១៤ |
| អាទិភាពទី២ : ការពង្រឹងអភិបាលកិច្ចហានិភ័យគ្រោះមហន្តរាយ ដើម្បីគ្រប់គ្រង ហានិភ័យគ្រោះមហន្តរាយ | ................. | ១៧ |
| អាទិភាពទី៣ : ការវិនិយោគ នៅក្នុងការកាត់បន្ថយហានិភ័យ គ្រោះមហន្តរាយសម្រាប់ភាពធន់ | ............................... | ១៨ |
| អាទិភាពទី៤ : លើកកម្ពស់ការត្រៀមរៀបចំគ្រោះមហន្តរាយ សម្រាប់ការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និង "*ការស្ដាបនាឲ្យប្រសើរជាងមុន*" ក្នុងការស្ដារឡើងវិញ ការធ្វើឲ្យប្រសើរឡើងវិញ និងការកសាងឡើងវិញ | ..... | ២១ |
| តួនាទីរបស់ភាគីពាក់ព័ន្ធ | ....................................................................... | ២៣ |
| កិច្ចសហប្រតិបត្តិការអន្តរជាតិ និងភាពជាដៃគូជាសកល | ......................... | ២៤ |

## I. បុព្វកថា

**១**. ក្របខ័ណ្ឌការងារសេនដាយ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០១៥~២០៣០ ត្រូវបានអនុម័តនៅឯសន្និសីទពិភពលោកលើកទី៣ របស់អង្គការសហប្រជាជាតិស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដែលបានប្រព្រឹត្តិទៅចាប់ពីថ្ងៃទី១៤ ដល់ ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០១៥ នៅទីក្រុងសេនដាយ ខេត្តមីយ៉ាហ្គី ប្រទេសជប៉ុន ជាឲ្យឱកាសតែមួយគត់សម្រាប់ប្រទេសដើម្បីៈ

(**ក**) សេចក្តីសង្ខេបនៃការអនុម័ត បានផ្តោតទៅលើផែនការ និងសកម្មភាពតម្រង់ទិសនៃក្របខ័ណ្ឌការងារសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្រោយឆ្នាំ២០១៥។

(**ខ**) បញ្ចប់ការប៉ាន់ប្រមាណ និងការពិនិត្យឡើងវិញ នូវការអនុវត្តក្របខ័ណ្ឌការងារសកម្មភាពយូហ្គោ ២០០៥~២០១៥: ការកសាងភាពធន់របស់ប្រទេស និងសហគមន៍ទៅនឹងគ្រោះមហន្តរាយ។[១]

(**គ**) ពិនិត្យពិចារណា លើបទពិសោធន៍ទទួលបាន តាមរយៈយុទ្ធសាស្ត្រថ្នាក់តំបន់ និងជាតិ/ស្ថាប័ន និងផែនការសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងអនុសាសន៍របស់ពួកគេ ក៏ដូចជាកិច្ចព្រមព្រៀងពាក់ព័ន្ធនៅថ្នាក់តំបន់ ក្រោមការអនុវត្តក្របខ័ណ្ឌការងារសកម្មភាពយូហ្គោ។

(**ឃ**) កំណត់បញ្ជាក់ពីបែបបទ នៃកិច្ចសហប្រតិបត្តិការ ដោយផ្អែកលើការប្តេជ្ញាចិត្តក្នុងការអនុវត្តក្របខ័ណ្ឌការងារសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្រោយឆ្នាំ២០១៥។

(**ង**) កំណត់បញ្ជាក់ពីបែបបទសម្រាប់ការពិនិត្យឡើងវិញតាមកាលកំណត់ នៃការអនុវត្តក្របខ័ណ្ឌការងារសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្រោយឆ្នាំ២០១៥។

**២**. នៅអំឡុងពេលនៃសន្និសីទពិភពលោក បណ្តារដ្ឋមួយចំនួន ក៏បានបញ្ជាក់ជាថ្មីឡើងវិញ នូវការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការកសាងភាពធន់[២] ទៅនឹងគ្រោះមហន្តរាយ ដែលត្រូវដោះស្រាយជាមួយនឹងន័យថ្មីបន្ទាន់ក្នុងបរិបទ នៃការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងការលុបបំបាត់ភាពក្រីក្រ តាមការសមស្រប ដើម្បីធ្វើសមាហរណ

កម្មទៅក្នុងគោលនយោបាយ ផែនការ កម្មវិធី និងថវិកានៅគ្រប់កម្រិត និងដោយបានចាត់ទុកក្នុងក្របខ័ណ្ឌការងារពាក់ព័ន្ធ។

## ក្របខ័ណ្ឌការងារសកម្មភាពហ្យូហ្គោៈ មេរៀនបទពិសោធន៍ ការខ្វះខាតដែលបានកំណត់បញ្ជាក់ និងបញ្ហាប្រឈមនាពេលអនាគត

៣. ចាប់តាំងពីការអនុម័តនៃក្របខ័ណ្ឌការងារសកម្មភាពហ្យូហ្គោនៅឆ្នាំ២០០៥ ដូចដែលបានចងក្រងជាឯកសារនៅក្នុងរបាយការណ៍ការរីកចម្រើនថ្នាក់ជាតិ និងតំបន់ ស្តីពីការអនុវត្តរបស់ខ្លួនក៏ដូចជានៅក្នុងរបាយការណ៍របស់ពិភពលោកដទៃទៀត ការរីកចម្រើនដែលសម្រេចបានក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ នៅមូលដ្ឋាន ថ្នាក់ជាតិ តំបន់ និងពិភពលោកដោយប្រទេស និងគ្រប់ភាគីពាក់ព័ន្ធផ្សេងទៀត ដែលឈានទៅដល់ការថយចុះចំនួននៃមរណៈភាពចំពោះករណីនៃមុខសញ្ញាគ្រោះថ្នាក់មួយចំនួន។[៣] ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយគឺជាគុណប្រយោជន៍នៃការវិនិយោគក្នុងការបង្ការនូវការខាតបង់នាពេលអនាគត។

---

[១] A/ CONF. ២០៦/ ៦ និង Corr. ១ ជំពូក I សេចក្តីសម្រេច ២។

[២] ភាធន់ត្រូវបានកំណត់: "សមត្ថភាពរបស់ប្រព័ន្ធ សហគមន៍ ឬសង្គម ដែលរងផលប៉ះពាល់ដោយមុខសញ្ញាគ្រោះថ្នាក់ ដើម្បីទប់សម្រាលសម្រួលទៅតាម និងស្តារឡើងវិញពីផលប៉ះពាល់ដោយមុខសញ្ញាគ្រោះថ្នាក់បានទាន់ពេលវេលា និងមានប្រសិទ្ធិភាព រួមទាំងតាមរយៈការអភិរក្ស និងការស្តារឡើងវិញ នូវរចនាសម្ព័ន្ធ និងដំណើរការ មានសារៈសំខាន់ជាមូលដ្ឋានរបស់ខ្លួន" ការិយាល័យអង្គការសហប្រជាជាតិ សម្រាប់ការកាត់បន្ថយហានិភ័យ គ្រោះមហន្តរាយ (UNISDR) "វាក្យសព្ទបច្ចេកទេសស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយរបស់ UNISDR ឆ្នាំ២០០៩" ទីក្រុងហ្សឺណែវ ខែឧសភា ឆ្នាំ២០០៩ (http://www.unisdr.org/we/inform/terminology)។

[៣] មុខសញ្ញាគ្រោះថ្នាក់ត្រូវបានកំណត់នៅក្នុងក្របខ័ណ្ឌការងារសកម្មភាពហ្យូហ្គោៈ "ព្រឹត្តិការណ៍មួយ បាតុភូតមួយ ឬសកម្មភាពរបស់មនុស្ស ដែលជាសក្តានុភាពអាចធ្វើឲ្យខូចខាតជារូបវន្ត រួមមានការបាត់បង់អាយុជីវិត ឬរងរបួស ខូចខាត និងបាត់បង់ទ្រព្យសម្បត្តិ រាំងស្ទះដល់សង្គមនិងសេដ្ឋកិច្ច ឬខូចខាតបរិស្ថាន។ មុខសញ្ញាគ្រោះថ្នាក់អាចរួមទាំងល័ក្ខខ័ណ្ឌមិនទាន់កើតឡើង នឹងអាចជាតំណាងឲ្យការគំរាមកំហែងនាអនាគត និងអាចមានប្រភពដើមផ្សេងគ្នាៈ ធម្មជាតិ (ភូមិសាស្ត្រ ឧតុនិយមជលសាស្ត្រ និងជីវសាស្ត្រ) ឬបង្កដោយដំណើរការរបស់មនុស្ស (ការខូចខាតបរិស្ថាន និងមុខសញ្ញាគ្រោះថ្នាក់បច្ចេកវិជ្ជា) ។

ប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយរួមចំណែកដល់ការអភិវឌ្ឍប្រកប ដោយនិរន្តរភាព។ ប្រទេសនានាបានបង្កើនសមត្ថភាពរបស់ពួកគេ ក្នុងការគ្រប់គ្រងហានិភ័យ គ្រោះមហន្តរាយ។ យន្តការអន្តរជាតិសម្រាប់ការអភិវឌ្ឍ យុទ្ធសាស្ត្រណែនាំ ការសម្រប សម្រួល និងភាពជាដៃគូក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដូចជាវេទិកាពិភពលោក សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនិងវេទិកាថ្នាក់តំបន់សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ក៏ដូចជាវេទិកាសហប្រតិបត្តិការអន្តរជាតិ និងតំបន់ពាក់ព័ន្ធផ្សេង ទៀតក្នុងការអភិវឌ្ឍគោលនយោបាយ យុទ្ធសាស្ត្រ និងការអភិវឌ្ឍនៃចំណេះដឹង និងការរៀន សូត្រពីគ្នាទៅវិញទៅមក។ជារួមក្របខ័ណ្ឌការងារសកម្មភាពយូហ្គោ គឺជាឧបករណ៍ដ៏សំខាន់សម្រាប់លើកកម្ពស់ការយល់ដឹងស្ថាប័ន និងសាធារណៈ ធ្វើឲ្យមានការប្តេជ្ញាចិត្តខាង នយោបាយ និងផ្តោតការយកចិត្តទុកដាក់ លើសកម្មភាពគ្របដណ្តប់ទូលំទូលាយ របស់ភាគី ពាក់ព័ន្ធនៅគ្រប់កម្រិត។

៤. អស់រយៈពេល ១០ឆ្នាំដូចគ្នា ទោះបីជាយ៉ាងណាក៏ដោយ គ្រោះមហន្តរាយបានបន្តកើនឡើងកាន់តែធ្ងន់ធ្ងរ ហើយជាលទ្ធផល សុខុមាលភាព និងសុវត្ថិភាពរបស់ប្រជាជន សហគមន៍ និងបណ្តាប្រទេសទាំងមូល ត្រូវបានទទួលរងផលប៉ះពាល់។ ប្រជាជនជាង៧០០ ពាន់នាក់បានបាត់បង់ជីវិត ជាង១.៤ លាននាក់បានរងរបួស និងប្រមាណ ២៣ លាននាក់ គ្មានផ្ទះសម្បែងដែលជាលទ្ធផលបង្កដោយគ្រោះមហន្តរាយ។ ជារួមច្រើនជាង ១.៥ ពាន់លាននាក់បានទទួលរងផលប៉ះពាល់ដោយគ្រោះមហន្តរាយប្រភេទផ្សេងៗគ្នា។ ស្ត្រី កុមារ និងប្រជាជនដែលស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះ បានទទួលរងផលប៉ះពាល់ ក្នុងអត្រាខុសៗគ្នា ។ ការខាតបង់សេដ្ឋកិច្ចជាសរុបមានជាង១.៣ ពាន់លានដុល្លារ។ លើសពីនេះទៀតនៅចន្លោះរវាងឆ្នាំ២០០៨ និងឆ្នាំ២០១២មានប្រជាជនចំនួន១៩៤លាននាក់ត្រូវបានផ្លាស់ទីលំនៅដោយសារគ្រោះមហន្តរាយ។ គ្រោះមហន្តរាយជាច្រើនប្រភេទ បានធ្វើឲ្យកាន់តែធ្ងន់ធ្ងរឡើងដោយការប្រែប្រួលអាកាសធាតុ និងការកើនឡើងកាន់តែញឹកញាប់ និងធ្ងន់ធ្ងរ រាំងស្ទះដល់ការរីកចម្រើន ឆ្ពោះទៅការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ ភស្តុតាងបង្ហាញថា កម្រិតរងគ្រោះមកលើប្រជាជន និងទ្រព្យសម្បត្តិក្នុងគ្រប់ប្រទេស បានកើនឡើងលឿនជាង ភាពងាយរងគ្រោះ[៤] បានថយចុះ ប៉ុន្តែប្រភេទហានិភ័យថ្មី បានកកើតឡើង និងការបាត់បង់ ដោយគ្រោះមហន្តរាយមានការកើនឡើង ជាសំខាន់លើផ្នែកសេដ្ឋកិច្ច សង្គម សុខភាព វប្បធម៌ និងផលប៉ះពាល់បរិស្ថាន នៅក្នុងរយៈពេលខ្លី មធ្យម និងវែង ជាពិសេសនៅកម្រិតមូលដ្ឋាន សហគមន៍។ វិសាលភាពគ្រោះមហន្តរាយតូចៗកើតឡើងជាញឹកញាប់ និងគ្រោះមហន្តរាយ អូសបន្លាយជាពិសេសប៉ះពាល់ដល់សហគមន៍ គ្រួសារ និងសហគ្រាសធុនតូច និងមធ្យម និងបង្កើតបានជាចំនួនភាគរយខ្ពស់នៃការបាត់បង់សរុប។ គ្រប់ប្រទេស ជាពិសេសបណ្តាប្រទេសកំពុង

អភិវឌ្ឍន៍មានអត្រាមរណៈ និងការបាត់បង់សេដ្ឋកិច្ចក្នុងអត្រាខ្ពស់ខុសៗគ្នា បានប្រឈមទៅនឹងកម្រិតកំណើន នៃលទ្ធភាពចំណាយមិនជាក់លាក់ និងប្រឈមទៅនឹងការឆ្លើយតបផ្នែកហិរញ្ញវត្ថុ និងកាតព្វកិច្ចផ្សេងទៀត។

**៥**. ជាការបន្ទាន់ និងសំខាន់ឆ្ពោះទៅការប្រមើលទុកជាមុននោះ ផែនការសម្រាប់នឹងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ត្រូវឲ្យកាន់តែស័ក្តសិទ្ធិថែមទៀត ដើម្បីការពារប្រជាជន សហគមន៍ និងប្រទេស ជីវភាពរស់នៅពួកគេ សុខភាព កេរតំណែលវប្បធម៌ ទ្រព្យសកម្មសង្គមសេដ្ឋកិច្ច និងប្រព័ន្ធអេកូឡូស៊ី ហេតុដូច្នេះហើយ គឺត្រូវពង្រឹងភាពធន់របស់ពួកគេ។

**៦**. បង្កើនការងារដើម្បីកាត់បន្ថយកម្រិតរងគ្រោះ និងភាពងាយរងគ្រោះ ក្នុងការទប់ស្កាត់នូវការកកើតនៃហានិភ័យគ្រោះមហន្តរាយថ្មី និងការទទួលខុសត្រូវខ្ពស់លើការកកើតហានិភ័យគ្រោះមហន្តរាយ ដែលតម្រូវឲ្យមាននៅគ្រប់កម្រិត។ បន្ថែមលើ សកម្មភាពចំពោះមុខតម្រូវការឆ្ពោះទៅការផ្តោតលើការផ្តើមពិនិត្យដោះស្រាយគំនាស់ហានិភ័យគ្រោះមហន្តរាយ ដូចជាផលវិបាកនៃភាពក្រីក្រ វិសមភាព ការប្រែប្រួលអាកាសធាតុ និងភាពដែលអាចប្រែប្រួលបាននគរូបនីយកម្ម ដោយគ្មានផែនការគ្រោងទុក ការគ្រប់គ្រងដីធ្លីមិនបានល្អ និងកត្តាគួបផ្សំដែលនាំឲ្យខូចខាតមួយចំនួន ដូចជាការផ្លាស់ប្តូរប្រជាសាស្ត្រ ការរៀបចំស្ថាប័នទន់ខ្សោយ គ្មានគោលនយោបាយទាក់ទងនឹងព័ត៌មានហានិភ័យ ខ្វះខាតបទដ្ឋានគតិយុត្ត និងការលើកទឹកចិត្តសម្រាប់ការវិនិយោគផ្នែកឯកជន លើការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ បណ្តាញផ្គត់ផ្គង់មានលក្ខណៈស្មុគស្មាញ បច្ចេកវិទ្យានៅមានកំណត់ ការប្រើធនធានធម្មជាតិ គ្មាននិរន្តរភាព ការធ្លាក់ចុះប្រព័ន្ធអេកូឡូស៊ី ជំងឺឆ្លង និងរោគរាតត្បាត។ លើសពីនេះ វាគឺជាការចាំបាច់ដើម្បីបន្តពង្រឹងអភិបាលកិច្ចល្អ ក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយថ្នាក់ជាតិ តំបន់ និងសកល និងការលើកកម្ពស់ការត្រៀមរៀបចំ និងការសម្របសម្រួលជាតិ សម្រាប់ការឆ្លើយតបគ្រោះមហន្តរាយ ការធ្វើឲ្យប្រសើរឡើងវិញ និងការកសាងឡើងវិញ និងការប្រើប្រាស់ការស្តារឡើងវិញក្រោយគ្រោះមហន្តរាយ និងការកសាងឡើងវិញដើម្បី *"ការស្ថាបនាឲ្យប្រសើរជាងមុន"* ដែលត្រូវបានគាំទ្រ និងពង្រឹងដោយបែបបទនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ។

[៤] ភាពងាយរងគ្រោះត្រូវបានកំណត់នៅក្នុងក្របខ័ណ្ឌការងារសកម្មភាពយូហ្គោដូចជា "ល័ក្ខខ័ណ្ឌដែលបានកំណត់ដោយកត្តា ធម្មជាតិ សង្គម សេដ្ឋកិច្ច និងបរិស្ថាន ឬដំណើរការដែលសហគមន៍ ងាយទទួលរងគ្រោះ និងផលប៉ះពាល់ដោយមុខសញ្ញាគ្រោះថ្នាក់"។

៧. ត្រូវតែមាន វិធីសាស្ត្រត្រៀមបង្ការទូលំទូលាយបន្ថែមទៀត ដោយផ្តោតលើប្រជាជនជាស្នូលទៅនឹងហានិភ័យគ្រោះមហន្តរាយ។ ការប្រតិបត្តិ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ចាំបាច់ត្រូវផ្អែកលើពហុមុខសញ្ញាគ្រោះថ្នាក់ និងពហុវិស័យ រួមទាំងការដែលអាចឈានបានទៅដល់ ក្នុងបទបញ្ញាដែលមានសមត្ថភាព និងប្រសិទ្ធភាព។ ខណៈដែលមានការទទួល ស្គាល់ពីតួនាទីដឹកនាំ បទដ្ឋានគតិយុត្ត និងការសម្របសម្រួលរបស់ពួកគេ រដ្ឋាភិបាលគួរចូល រួមជាមួយគ្រប់ភាគីពាក់ព័ន្ធ រួមទាំងស្ត្រី យុវជន និងកុមារ ជនពិការ ប្រជាជនក្រីក្រ ទេសន្តរ ប្រវេសន៍ ជនជាតិដើមភាគតិច អ្នកស្ម័គ្រចិត្ត អ្នកអនុវត្តនៅតាមសហគមន៍ និងមនុស្សវ័យ ចំណាស់ នៅក្នុងការរិះរក និងការអនុវត្ត គោលនយោបាយ ផែនការ និងស្តង់ដា។ ចេញពីនោះ ក៏មានតម្រូវការសម្រាប់វិស័យ សាធារណៈ វិស័យឯកជន និងអង្គការសង្គមស៊ីវិល ក៏ដូចជា បណ្ឌិតសភា និងស្ថាប័ន ស្រាវជ្រាវវិទ្យាសាស្ត្រ ដើម្បីធ្វើការយ៉ាងជិតជាមួយគ្នា និងបង្កើតកាលានុវត្តភាព សម្រាប់កិច្ចសហការ និងសម្រាប់ធុរកិច្ច ដើម្បីធ្វើសមាហរណកម្មហានិភ័យគ្រោះមហន្តរាយ ទៅក្នុងការគ្រប់គ្រង នៃការអនុវត្តរបស់ខ្លួន។

៨. កិច្ចសហប្រតិបត្តិការអន្តរជាតិ តំបន់ អនុតំបន់ និងឆ្លងដែន នៅតែជាស្នូលក្នុងការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋ អាជ្ញាធរថ្នាក់ជាតិ និងមូលដ្ឋានរបស់ខ្លួន ក៏ដូចជាសហគមន៍ និងធុរកិច្ចដើម្បីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ យន្តការដែលមានស្រាប់ អាចតម្រូវឲ្យមានការពង្រឹងដើម្បីផ្តល់នូវការគាំទ្រប្រកបដោយប្រសិទ្ធភាព និងសម្រេចនូវការអនុវត្តបានល្អប្រសើរ។ ប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសមានការអភិវឌ្ឍតិចតួច រដ្ឋដែនកោះតូចៗ កំពុងអភិវឌ្ឍន៍ ប្រទេសមិនជាប់ដែនសមុទ្រកំពុងអភិវឌ្ឍន៍ និងប្រទេសអាហ្វ្រិក ក៏ដូចជាបណ្តាប្រទេសមានចំណូលមធ្យម ប្រទេសកំពុងប្រឈមមុខនឹងបញ្ហាជាក់លាក់ ត្រូវផ្តល់ការយកចិត្តទុកដាក់ ជាពិសេស និងការគាំទ្រដើម្បីបង្កើនប្រភពធនធានក្នុងស្រុក និងសមត្ថភាពតាមរយៈបណ្តាញ ទ្វេភាគី និងពហុភាគី ដើម្បីធានាឲ្យបានគ្រប់គ្រាន់ មាននិរន្តរភាព និងមធ្យោបាយពេលវេលា នៃការការអនុវត្ត ក្នុងការកសាងសមត្ថភាព ជំនួយផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស និងការផ្ទេរបច្ចេកវិទ្យា ដោយអនុលោមទៅតាមការប្តេជ្ញាចិត្តជាអន្តរជាតិ។

៩. ជារួមក្របខ័ណ្ឌការងារសកម្មភាពយូហ្គោ បានផ្តល់ការណែនាំដ៏សំខាន់នៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងរួមចំណែកដល់ការរីកចម្រើនឆ្ពោះទៅរកការសម្រេចបាន នូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ ទោះបីជាយ៉ាងណាក៏ដោយ ការអនុវត្តរបស់ខ្លួន បានធ្វើឲ្យលេចឡើងនូវចំនួននៃចន្លោះប្រហោង ក្នុងការដោះស្រាយកត្តាហានិភ័យគ្រោះមហន្តរាយមូលដ្ឋានក្នុងបទប្បញ្ញត្តិគោលដៅ និងសកម្មភាពអាទិភាព[៥] ជាតម្រូវការក្នុងការជម្រុញភាពធន់គ្រោះមហន្តរាយនៅគ្រប់កម្រិត និងធានាដល់មធ្យោបាយអនុវត្តន៍

ឲ្យបានគ្រប់គ្រាន់។ ចន្លោះប្រហោងនេះបាន បង្ហាញពីតម្រូវការក្នុងការអភិវឌ្ឍក្របខ័ណ្ឌសកម្មភាពតម្រង់ទិសមួយដែលរដ្ឋាភិបាល និងគ្រប់ភាគីពាក់ព័ន្ធអាចអនុវត្តក្នុងលក្ខណៈគាំទ្រ និងជួយបំពេញក្នុងការកំណត់បញ្ជាក់ពីហានិភ័យគ្រោះមហន្តរាយ អាចត្រូវបានគ្រប់គ្រង និងដឹកនាំការវិនិយោគ ដើម្បីលើកកម្ពស់ភាពធន់។

**១០**. ដប់ឆ្នាំក្រោយពីក្របខ័ណ្ឌការងារសកម្មភាពយូហ្គោ គ្រោះមហន្តរាយនៅតែបន្តធ្វើឲ្យប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

**១១**. ការចរចារបស់អន្តររដ្ឋាភិបាល លើរបៀបវារៈអភិវឌ្ឍន៍ក្រោយឆ្នាំ២០១៥ ហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍ ការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយគឺផ្តល់ដល់សហគមន៍អន្តរជាតិ ជាមួយកាលានុវត្តភាព ដើម្បីពង្រឹងរាល់គោលនយោបាយ ស្ថាប័ន គោលដៅ សូចនាករ និងប្រព័ន្ធវិធានការដែលពាក់ព័ន្ធ សម្រាប់ការអនុវត្ត ដោយគោរពតាមអាណត្តិនីមួយៗរបស់ពួកគេ។ ធានាដល់ការភ្ជាប់ទំនាក់ទំនងដែលគួរឲ្យជឿបានសមស្រប រវាងដំណើរការទាំងនេះ នឹងរួមចំណែកដើម្បីការកសាងភាពធន់ និងការសម្រេចគោលបំណងសកលដល់ការលុបបំបាត់ភាពក្រីក្រ។

**១២**. ការរំលឹកឡើងវិញនូវលទ្ធផលនៃសន្និសីទអង្គការសហប្រជាជាតិ ស្តីអំពីការអភិវឌ្ឍប្រកបដោយនិរន្តរភាព ឆ្នាំ២០១២ "*អនាគតដែលយើងចង់បាន*[៦] ដែលត្រូវបានគេហៅសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការកសាងភាពធន់ទៅនឹងគ្រោះមហន្តរាយដែលត្រូវដោះស្រាយជាមួយនឹងន័យថ្មីបន្ទាន់ នៅក្នុងបរិបទនៃការអភិវឌ្ឍ ប្រកបដោយនិរន្តរភាព និងការលុបបំបាត់ភាពក្រីក្រ ដើម្បីធ្វើសមាហរណកម្មនៅគ្រប់កម្រិតសមស្រប។ សន្និសីទក៏បានបញ្ជាក់ជាថ្មីនូវរាល់គោលការណ៍នៃសេចក្តីថ្លែងការណ៍របស់ទីក្រុងរីយ៉ូ (Rio) ស្តីអំពីបរិស្ថាន និងការអភិវឌ្ឍ។[៧]

---

[៥] ក្របខ័ណ្ឌការងារសកម្មភាពអាទិភាពយូហ្គោ ២០០៥-២០១៥ គឺ៖ (១) ធានាដល់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ គឺជាអាទិភាពរបស់ថ្នាក់ជាតិ ដែលមានស្ថាប័នជាមូលដ្ឋានដ៏រឹងមាំសម្រាប់ការអនុវត្តន៍; (២) កំណត់បញ្ជាក់ ប៉ាន់ប្រមាណ និងត្រួតពិនិត្យតាមដានហានិភ័យគ្រោះមហន្តរាយ និងលើកកម្ពស់ការជូនដំណឹងជាមុន; (៣) ប្រើចំណេះដឹង របកគំហើញថ្មី និងការអប់រំ ដើម្បីកសាងវប្បធម៌សុវត្ថិភាព និងភាពធន់នៅគ្រប់កម្រិត; (៤) កាត់បន្ថយកត្តាហានិភ័យមូលដ្ឋាន; និង (៥) ពង្រឹងការត្រៀមរៀបចំ សម្រាប់ការឆ្លើយតបគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធិភាពនៅគ្រប់កម្រិត។

[៦] សេចក្តីសម្រេចចិត្តរបស់អង្គការសហប្រជាជាតិលេខ ៦៦/២៨៨ ឧបសម្ព័ន្ធ។[៧] របាយការណ៍របស់សន្និសីទអង្គការសហប្រជាជាតិស្តីពីបរិស្ថាន និងការអភិវឌ្ឍទីក្រុងរីយ៉ូ នាថ្ងៃទី ៣-១៤ ខែមិថុនាឆ្នាំ១៩៩២ វ៉ូលូម I. សេចក្តីសម្រេចចិត្តនេះបានអនុម័តដោយសន្និសីទ (ការបោះពុម្ពរបស់អង្គការសហ ប្រជាជាតិ ចេញផ្សាយលេខ អ៊ី.៩៣.អាយ.៨ និងកំណែ) សេចក្តីសម្រេចចិត្ត១ ឧបសម្ព័ន្ធ I។

**១៣**. ការដោះស្រាយលើការប្រែប្រួលអាកាសធាតុ ក៏ជាផ្នែកមួយនៃគំនាស់ហានិភ័យគ្រោះមហន្តរាយ ដោយគោរពតាមអាណត្តិនៃក្របខ័ណ្ឌអនុសញ្ញាអង្គការសហប្រជាជាតិស្តីអំពីការប្រែប្រួលអាកាសធាតុ[៨] ដែលតំណាងឲ្យកាលានុវត្តភាព ដើម្បីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដែលមានអត្ថន័យ និងមានទំនាក់ទំនងទាំស្រុងទៅនឹងដំណើរការរបស់អន្តររដ្ឋាភិបាល។

**១៤**. ឆ្លុះបញ្ចាំងទៅនឹងសារតានេះ និងដើម្បីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ វាជាតម្រូវការដើម្បីដោះស្រាយបញ្ហាប្រឈមដែលមានស្រាប់ និងរៀបចំសម្រាប់អនាគតមួយដោយផ្តោតលើ៖ ការតាមដានត្រួតពិនិត្យ ប៉ាន់ប្រមាណ និងការយល់ដឹងពីហានិភ័យគ្រោះមហន្តរាយ និងការចែករំលែកព័ត៌មានបែបនេះ និងរបៀបដែលវាត្រូវបានបង្កើតឡើង។ ពង្រឹងអភិបាលកិច្ចហានិភ័យគ្រោះមហន្តរាយ និងការសម្របសម្រួលនៅគ្រប់ស្ថាប័ន និងវិស័យពាក់ព័ន្ធ និងការចូលរួមពេញលេញ និងដែលមានអត្ថន័យនៃភាគីពាក់ព័ន្ធនៅគ្រប់កម្រិតសមស្រប។ ការវិនិយោគនៅក្នុងសេដ្ឋកិច្ច សង្គម សុខភាព វប្បធម៌ និងការអប់រំភាពធន់របស់ប្រជាជន សហគមន៍ និងប្រទេស និងនៅក្នុងបរិស្ថាន ក៏ដូចជាតាមរយៈបច្ចេកវិទ្យា និងការស្រាវជ្រាវ។ ការបង្កើនប្រព័ន្ធប្រកាសឲ្យដឹងមុនពីពហុមុខសញ្ញាគ្រោះថ្នាក់ ការត្រៀមរៀបចំ ការឆ្លើយតប ការស្តារឡើងវិញ ការធ្វើឲ្យប្រសើរឡើងវិញ និងការកសាងឡើងវិញ។ ដើម្បីបំពេញសកម្មភាព និងសមត្ថភាពថ្នាក់ជាតិ ចេញពីនោះក៏មានតម្រូវការចាំបាច់ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ រវាងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ និងរវាងរដ្ឋ និងបណ្តាអង្គការអន្តរជាតិ។

**១៥**. ក្របខ័ណ្ឌការងារបច្ចុប្បន្ននេះ នឹងត្រូវអនុវត្តន៍សម្រាប់ហានិភ័យដែលមានវិសាលភាពតូច និងធំជាញឹកញាប់ និងម្តងម្កាល គ្រោះមហន្តរាយភ្លាមៗ និងអូសបន្លាយ បានបង្កឡើងដោយមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ ឬដោយមនុស្ស ក៏ដូចជាមុខសញ្ញាគ្រោះថ្នាក់ និងហានិភ័យពាក់ព័ន្ធនឹងបរិស្ថាន បច្ចេកវិទ្យា និងជីវសាស្រ្ត។ វាមានគោលបំណងដើម្បីណែនាំការគ្រប់គ្រងពហុមុខ សញ្ញាគ្រោះថ្នាក់ នៃហានិភ័យគ្រោះមហន្តរាយ ក្នុងការអភិវឌ្ឍនៅគ្រប់កម្រិត នៅក្នុង និងការឆ្លងកាត់នៅគ្រប់វិស័យ។

---

[៨] បញ្ហានៃការប្រែប្រួលអាកាសធាតុ ដូចបានបានរៀបរាប់នៅក្នុងក្របខ័ណ្ឌបច្ចុប្បន្ននេះ នៅតែស្ថិតក្នុងអណត្តិរបស់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ស្ថិតនៅក្រោមសមត្ថកិច្ចរបស់ភាគីនៃអនុសញ្ញា។

## II. គោលបំណង និងលទ្ធផលរំពឹងទុក

**១៦**. ខណៈដែលមានការរីកចម្រើនមួយចំនួន ក្នុងការកសាងភាពធន់ និងការកាត់បន្ថយការបាត់បង់ និងខូចខាតដែលបានសម្រេច ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយជាច្រើនតម្រូវឲ្យមានការព្យាយាមតស៊ូ និងជានិរន្ត ជាមួយនឹងការផ្តោតដោយជាក់លាក់លើប្រជាជន[8] សុខភាព និងជីវភាពរស់នៅរបស់ពួកគេ និងបន្តតាមដានជាទៀងទាត់។ ការកសាងក្របខ័ណ្ឌការងារសកម្មភាពយូហ្គោ ជាមួយនឹងក្របខ័ណ្ឌការងារបច្ចុប្បន្ននេះ មានគោលបំណងដើម្បីសម្រេចបាននូវលទ្ធផលក្នុងរយៈពេល ១៥ឆ្នាំបន្ទាប់ដូចខាងក្រោមនេះ៖

*ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយជាច្រើន និងការបាត់បង់អាយុជីវិត ជីវភាពរស់នៅសុខភាព និងនៅក្នុងផ្នែកសេដ្ឋកិច្ច រូបវន្ត សង្គម វប្បធម៌ និងទ្រព្យសម្បត្តិបរិស្ថានរបស់មនុស្ស ធុរកិច្ច សហគមន៍ និងប្រទេស។*

សម្មិទ្ធិផលនៃលទ្ធផលនេះ តម្រូវឲ្យមានការប្តេជ្ញាចិត្តដ៏រឹងមាំ និងការចូលរួមរបស់អ្នកដឹកនាំនយោបាយនៅគ្រប់ប្រទេស និងគ្រប់កម្រិត ក្នុងការអនុវត្ត និងការបន្តតាមដានលើក្របខ័ណ្ឌការងារនេះ និងក្នុងការបង្កើតវត្ថុចាំបាច់។

**១៧**. ដើម្បីទទួលបាននូវលទ្ធផលរំពឹងទុក គោលបំណងដែលត្រូវបន្ត ដូចខាងក្រោម ៖

> *ការអនុវត្តត្រៀមបង្ការថ្មី និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដែលមានស្រាប់តាមរយៈការ អនុវត្ត សមាហរណកម្ម និងដែលរាប់បញ្ចូលទាំងផ្នែកសេដ្ឋកិច្ច រចនាសម្ព័ន្ធច្បាប់ សង្គម សុខភាព វប្បធម៌ អប់រំ បរិស្ថាន បច្ចេកវិទ្យា នយោបាយ និងវិធានការនៃស្ថាប័ន ដែលបង្ការ និងកាត់បន្ថយកម្រិតរងគ្រោះដោយមុខសញ្ញាគ្រោះថ្នាក់ និងភាពងាយរងគ្រោះពីគ្រោះមហន្តរាយ បង្កើនការត្រៀមរៀបចំ សម្រាប់ការឆ្លើយតប និងការស្តារឡើងវិញ និងការពង្រឹងភាពធន់។*

ក្នុងការសម្រេចបានគោលបំណងនេះ តម្រូវឲ្យមានការបង្កើនសមត្ថភាពការអនុវត្ត និងលទ្ធភាព របស់ប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសបណ្តាប្រទេសអភិវឌ្ឍន៍តិចតួច រដ្ឋដែនកោះតូចៗ កំពុងអភិវឌ្ឍន៍ ប្រទេសមិនជាប់ដែនសមុទ្រកំពុងអភិវឌ្ឍន៍ និងប្រទេសអាហ្វ្រិក ក៏ដូចជាបណ្តា ប្រទេសដែលមានប្រាក់ចំណូលមធ្យម កំពុងប្រឈមនឹងបញ្ហាជាក់លាក់ រួមមានការ

កៀរគរ នៃការគាំទ្រតាមរយៈ កិច្ចសហប្រតិបត្តិការអន្តរជាតិ សម្រាប់ល័ក្ខខ័ណ្ឌ នៃមធ្យោបាយសម្រាប់ការអនុវត្ត អនុលោមតាមអាទិភាពជាតិរបស់ពួកគេ។

**១៨**. ដើម្បីគាំទ្រដល់ការប៉ាន់ប្រមាណលើការរីកចម្រើនជាសកល ក្នុងការសម្រេចបាននូវលទ្ធផល និងគោលបំណងនៃក្របខ័ណ្ឌការងារនេះ គោលដៅជាសកលចំនួនប្រាំពីរត្រូវបានព្រមព្រៀង។ គោលដៅដែលបានគិតល្អិតល្អន់ទាំងនេះ នៅកម្រិតនៃពិភពលោក ហើយត្រូវបានបំពេញដោយការងារដើម្បីបង្កើតសូចនាករសមស្រប។ គោលដៅ និងសូចនាករជាតិ នឹងរួមចំណែកដល់ការសម្រេចបាននូវលទ្ធផល និងគោល បំណងនៃក្របខ័ណ្ឌការងារនេះ។ គោលដៅជាសកលចំនួនប្រាំពីរគឺៈ

(**ក**) កាត់បន្ថយយ៉ាងច្រើនគួរសម នូវមរណភាពដោយគ្រោះមហន្តរាយ នៃពិភពលោក គិតដល់ឆ្នាំ២០៣០ សំដៅបន្ទាបមធ្យមភាគមរណភាពនៃពិភពលោកក្នុង ១០០,០០០ រវាងឆ្នាំ ២០២០~២០៣០ ធៀបទៅនឹងឆ្នាំ ២០០៥~២០១៥។

(**ខ**) កាត់បន្ថយយ៉ាងច្រើនគួរសម នូវចំនួនប្រជាជនដែលប៉ះពាល់នៅទូទាំងពិភពលោកគិតដល់ឆ្នាំ២០៣០ សំដៅបន្ទាបមធ្យមភាគគណនាជាសកល ១០០,០០០ រវាងឆ្នាំ ២០២០~២០៣០ ធៀបទៅនឹង ឆ្នាំ២០០៥~២០១៥។[៩]

(**គ**) កាត់បន្ថយការបាត់បង់សេដ្ឋកិច្ច ដោយគ្រោះមហន្តរាយដោយផ្ទាល់ ដែលទាក់ទងទៅនឹងផលិតផលក្នុងស្រុកសរុប (GDP) គិតដល់ឆ្នាំ២០៣០។

(**ឃ**) កាត់បន្ថយយ៉ាងច្រើនគួរសមនូវការខូចខាត ដោយគ្រោះមហន្តរាយ មកលើហេដ្ឋារចនាសម្ព័ន្ធប្រកបដោយគ្រោះថ្នាក់ និងការបង្អាក់ដល់ដំណើរការផ្តល់សេវាជាមូលដ្ឋានក្នុងចំណោម ដែលមានជាមធ្យោបាយសុខាភិបាលនិងអប់រំ រួមទាំងតាមរយៈការអភិវឌ្ឍភាពធន់ទាំងឡាយគិតដល់ឆ្នាំ ២០៣០។

(**ង**) បង្កើនយ៉ាងច្រើនគួរសមចំនួននៃប្រទេស ដែលមានយុទ្ធសាស្ត្រការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយថ្នាក់ជាតិ និងមូលដ្ឋាន គិតដល់ឆ្នាំ២០២០។

---

[៩] ប្រភេទនៃប្រជាជនរងគ្រោះ នឹងត្រូវបានបកស្រាយនៅក្នុងដំណើរការ សម្រាប់ក្រោយការងារសេនដាយ ដែលបានសម្រេចដោយសន្និសីទ។

(ច) បង្កើនយ៉ាងច្រើនគួរសម នូវកិច្ចសហប្រតិបត្តិការអន្តរជាតិ របស់ប្រទេសកំពុងអភិវឌ្ឍន៍ តាមរយៈការគាំទ្រគ្រប់គ្រាន់ និងប្រកបដោយនិរន្តរភាព ដើម្បីបំពេញសកម្មភាពរបស់ជាតិ សម្រាប់ការអនុវត្តក្របខ័ណ្ឌការងារនេះគិតដល់ឆ្នាំ២០៣០។

(ឆ) បង្កើនយ៉ាងច្រើនគួរសមភាពប្រើប្រាស់បាន និងអាចយកមកប្រើប្រាស់បាន ដើម្បីការប៉ាន់ប្រមាណ និងព័ត៌មានហានិភ័យគ្រោះមហន្តរាយ និងប្រព័ន្ធប្រកាសឲ្យដឹងមុនពហុមុខសញ្ញាគ្រោះថ្នាក់ ដល់ប្រជាជន គិតដល់ឆ្នាំ២០៣០។

## III. គោលការណ៍នៃការណែនាំ

**១៩**. ដកស្រង់ចេញពីគោលការណ៍ដែលមាននៅក្នុងយុទ្ធសាស្ត្រទីក្រុងយូកូហាម៉ាសម្រាប់សុវត្ថិភាពពិភពលោក៖ គោលការណ៍ណែនាំសម្រាប់ការត្រៀមបង្ការគ្រោះមហន្តរាយ ធម្មជាតិ ការត្រៀមរៀបចំ ការកាត់បន្ថយគ្រោះថ្នាក់ និងផែនការសកម្មភាព[១០] របស់ខ្លួន និង ក្របខ័ណ្ឌការងារសកម្មភាពយូហ្គោ ការអនុវត្តនៃក្របខ័ណ្ឌការងារបច្ចុប្បន្ននេះនឹងត្រូវបាន ណែនាំដោយគោលការណ៍ដូចតទៅនេះ ខណៈដែលមានការយកចិត្តទុកដាក់ទៅលើកាលៈ ទេសៈជាតិ និងស្របនឹងច្បាប់ក្នុងប្រទេស ក៏ដូចជាកាតព្វកិច្ច និងការប្តេជ្ញាចិត្តរបស់អន្តរជាតិ៖

(ក) ប្រទេសនីមួយៗ មានភារកិច្ចទទួលខុសត្រូវជាចម្បងដើម្បីការពារ និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ រួមទាំងតាមរយៈកិច្ចសហប្រតិបត្តិការ ទ្វេភាគី អន្តរជាតិ តំបន់ អនុតំបន់ និងឆ្លងដែន។ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ គឺជាក្តីបារម្ភទូទៅសម្រាប់ប្រទេសទាំងអស់ និងកម្រិតនៃប្រទេសកំពុងអភិវឌ្ឍន៍ អាចបង្កើនប្រសិទ្ធភាព និងអនុវត្តគោលនយោបាយកាត់បន្ថយហានិភ័យគ្រោះមហន្តរាយថ្នាក់ជាតិ និងវិធានការ នៅក្នុងបរិបទនៃកាលៈទេសៈ និងសមត្ថភាពរៀងៗខ្លួន ដែលអាចត្រូវបានពង្រឹងបន្ថែមទៀតតាមរយៈល័ក្ខខ័ណ្ឌកិច្ចសហប្រតិបត្តិការអន្តរជាតិប្រកបដោយនិរន្តរភាព។

(ខ) ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ តម្រូវឲ្យចែករំលែក ការទទួលខុសត្រូវដោយរដ្ឋាភិបាលកណ្តាល អាជ្ញាធរជាតិពាក់ព័ន្ធ វិស័យ និងភាគីពាក់ព័ន្ធ តាមការសមស្របទៅនឹងកាលៈទេសៈជាតិរបស់ពួកគេ និងប្រព័ន្ធអភិបាលកិច្ច។

---

[១០] ឯកសារ A/CONF ១៧២/៩, ជំពូក១, សេចក្តីសម្រេច១, ឧបសម្ព័ន្ធ

(ឝ) ការគ្រប់គ្រងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ គឺមានបំណងការពារប្រជាជន និងទ្រព្យសម្បត្តិ សុខភាព ជីវភាពរស់នៅ និងទ្រព្យសកម្មផលិតកម្មរបស់ពួកគេក៏ដូចជាទ្រព្យសម្បត្តិ វប្បធម៌ និងបរិស្ថាន នៅខណៈនៃការលើកកម្ពស់ និងការពារគ្រប់សិទ្ធិ មនុស្សរួមទាំងសិទ្ធិក្នុងការអភិវឌ្ឍ។

(ឃ) ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ តម្រូវឲ្យមានការចូលរួមគ្រប់របស់ទាំងអស់នៃសង្គម និងភាពជាដៃគូ។ វាក៏តម្រូវឲ្យមានផងដែរនូវការផ្តល់អំណាច និងការចូលរួមអាចចូលរួមបាន និងមិនរើសអើង ដោយយកចិត្តទុកដាក់ពិសេសដល់ប្រជាជនភាគតិចដែលរងផលប៉ះពាល់ដោយ គ្រោះមហន្តរាយ ជាពិសេសអ្នកក្រីក្របំផុត។ យេនឌ័រ អាយុ ពិការភាព និងគោលគំនិតវប្បធម៌ ក្នុងគ្រប់និន្នាការនយោបាយ និងការអនុវត្ត លើកកម្ពស់ភាពជាអ្នកដឹកនាំជាស្ត្រី និងយុវជន ហើយនៅក្នុងបរិបទនេះ ការយកចិត្តទុកដាក់ពិសេស គួរតែត្រូវបានផ្តល់ទៅលើការធ្វើឲ្យកាន់តែប្រសើរ នៃការរៀបចំការងារស្ម័គ្រចិត្តរបស់ប្រជាពលរដ្ឋ។

(ង) ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការគ្រប់គ្រងអាស្រ័យទៅលើយន្តការសម្របសម្រួលផ្ទៃក្នុង និងវិស័យទាក់ទិន និងជាមួយភាគីពាក់ព័ន្ធនៅគ្រប់កម្រិត។ វាតម្រូវឲ្យមានការចូលរួមពីស្ថាប័នរដ្ឋទាំងអស់ ទាំងផ្នែកប្រតិបត្តិ ផ្នែកនីតិបញ្ញត្តិនៅថ្នាក់ជាតិ និងមូលដ្ឋាន និងរៀបចំការទទួលខុសត្រូវឲ្យបានច្បាស់លាស់ នៅទូទាំងផ្នែកសាធារណៈ ភាគីពាក់ព័ន្ធផ្នែកឯកជន រួមទាំងធុរកិច្ច និងបណ្ឌិតសភា ដើម្បីធានាដល់ការផ្សព្វផ្សាយទៅវិញទៅមកភាពជាដៃគូ ការបំពេញតួនាទី ការទទួលខុសត្រូវខ្ពស់ និងការបន្តតាមដាន។

(ច) ខណៈពេលដែលតួនាទី ការសម្របសម្រួល ការណែនាំ និងការជួយធ្វើទៅបានរបស់រដ្ឋាភិបាលថ្នាក់ជាតិ និងសហព័ន្ធនៅតែមានសារៈសំខាន់នោះ វាគឺជាការចាំបាច់ក្នុងការផ្តល់សិទ្ធិអំណាចដល់អាជ្ញាធរ មូលដ្ឋាន និងមូលដ្ឋានសហគមន៍ ដើម្បីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ តាមរយៈ ប្រភព ធនធាន ការលើកទឹកចិត្ត និងការទទួលខុសត្រូវក្នុងការធ្វើសេចក្តីសម្រេចតាមការសមស្រប។

(ឆ) ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ តម្រូវឲ្យមានដំណោះស្រាយពហុមុខសញ្ញាគ្រោះថ្នាក់ និងការសម្រេចចិត្តលើព័ត៌មានហានិភ័យ ដោយផ្អែកលើការផ្លាស់ប្តូរ និងផ្សព្វផ្សាយទិន្នន័យសរុបជាចំហ រួមទាំងយេនឌ័រ អាយុ និងពិការភាព ក៏ដូចជាការអាចទទួលបាន និងធ្វើបច្ចុប្បន្នភាពងាយស្រួល អាចយល់បាន មានមូលដ្ឋានវិទ្យាសាស្ត្រ មិនមែនជាព័ត៌មានរសើប និងបំពេញដោយចំណេះដឹងបែបប្រពៃណី។

(**ជ**) ការអភិវឌ្ឍ ការពង្រឹង និងការអនុវត្ត នៃគោលនយោបាយពាក់ព័ន្ធ ផែនការ ការប្រតិបត្តិ និងយន្តការ តម្រូវទៅនឹងគោលបំណងរួមសមស្រប ទាក់ទងការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងកំណើន សន្តិសុខស្បៀង សុខភាព និងសុវត្ថិភាព ការប្រែប្រួលអាកាសធាតុ និងការប្រែប្រួលការគ្រប់គ្រងបរិស្ថាន និងរបៀបវារៈនៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ គឺជាការចាំបាច់ដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

(**ឈ**) ខណៈដែលគំនាស់ នៃទំហំហានិភ័យគ្រោះមហន្តរាយនៅកម្រិតមូលដ្ឋាន ជាតិ តំបន់ ឬពិភពលោក ហានិភ័យគ្រោះមហន្តរាយមាននៅមូលដ្ឋាន និងមានលក្ខណៈជាក់លាក់ ដែលត្រូវបានដឹងសម្រាប់ការដាក់ចេញជាវិធានការដើម្បីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

(**ញ**) ការដោះស្រាយ កត្តាមូលដ្ឋានហានិភ័យគ្រោះមហន្តរាយ តាមរយៈការវិនិយោគលើផ្នែកព័ត៌មានហានិភ័យគ្រោះមហន្តរាយ ផ្នែកសាធារណៈ និងឯកជន មានគុណប្រយោជន៍ជាងការពឹងផ្អែកជាសំខាន់លើការឆ្លើយតប និងស្តារឡើងវិញក្រោយគ្រោះមហន្តរាយ និងរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

(**ដ**) ក្នុងការស្តារឡើងវិញក្រោយគ្រោះមហន្តរាយ ដំណាក់កាលនៃការធ្វើឲ្យប្រសើរជាងមុន និងការកសាងឡើងវិញ វាជាការសំខាន់ដើម្បីទប់ស្កាត់នូវការកកើត និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដោយ *"ការស្ថាបនាឲ្យប្រសើរជាងមុន"* និងការបង្កើនការអប់រំ និងការយល់ដឹងជាសាធារណៈ អំពីហានិភ័យគ្រោះមហន្តរាយ។

(**ឋ**) ប្រសិទ្ធភាព និងអត្ថន័យភាពជាដៃគូសកល និងការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ តទៅទៀតរួមមានការបំពេញនូវការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការ ដោយបណ្តាប្រទេសអភិវឌ្ឍន៍ គឺមានសារៈសំខាន់សម្រាប់ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធិភាព។

(**ឌ**) ប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច រដ្ឋកំពុងអភិវឌ្ឍន៍នៃដែនកោះតូចៗ ប្រទេសកំពុងអភិវឌ្ឍន៍មិនជាប់ដែនសមុទ្រ និងប្រទេសអាហ្វ្រិក ក៏ដូចជាប្រទេសមានប្រាក់ចំណូលមធ្យម និងបណ្តាប្រទេសផ្សេងទៀតកំពុងប្រឈមនឹងហានិភ័យគ្រោះមហន្តរាយជាក់លាក់ ដែលត្រូវផ្តល់ការគាំទ្រសេចក្តីត្រូវការគ្រប់គ្រាន់ មាននិរន្តរភាព និងទាន់ពេលវេលា រួមទាំងតាមរយៈហិរញ្ញវត្ថុ ការផ្ទេរបច្ចេកវិទ្យា និងការកសាង

សមត្ថភាពពីបណ្តាប្រទេស និងដៃគូអភិវឌ្ឍន៍ ដោយបានរៀបចំតាមតម្រូវការ និងអាទិភាព របស់ខ្លួនតាម ការកំណត់របស់ពួកគេ។

## IV. **សកម្មភាពអាទិភាព**

**២០**. យកចិត្តទុកដាក់គិតគូរ លើបទពិសោធន៍ទទួលបានតាមរយៈការអនុវត្ត ក្របខ័ណ្ឌការងារសកម្មភាពយូហ្គោ និងបន្តគោលដៅ និងលទ្ធផលរំពឹងទុក ជាការចាំបាច់សម្រាប់សកម្មភាពដែលផ្តោតលើគ្រប់វិស័យ ដោយរដ្ឋនៅមូលដ្ឋាន ថ្នាក់ជាតិ តំបន់ និងកម្រិតសកលលោក នៅក្នុងវិស័យអាទិភាព ដែលជាបន្តបន្ទាប់ចំនួនបួនៈ

១. ការយល់ដឹងអំពីហានិភ័យគ្រោះមហន្តរាយ
២. ការពង្រឹងអភិបាលកិច្ចហានិភ័យគ្រោះមហន្តរាយ ដើម្បីគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ
៣. ការវិនិយោគនៅក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ សម្រាប់ភាពធន់
៤. បង្កើនការត្រៀមរៀបចំ សម្រាប់ការឆ្លើយតបនឹងគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព និងដើម្បី *"ការស្តាបនាឲ្យប្រសើរជាងមុន"* ក្នុងការស្តារឡើងវិញ ការធ្វើឲ្យប្រសើរឡើងវិញ និងការកសាង ឡើងវិញ។

**២១**. នៅក្នុងដំណោះស្រាយរបស់ពួកគេ ដើម្បីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ រដ្ឋ តំបន់ អង្គការអន្តរជាតិ និងភាគីពាក់ព័ន្ធផ្សេងទៀត គួរគិតគូរពិចារណាលើសកម្មភាពគន្លឹះ ដែលរៀបរាប់ក្រោមវិស័យអាទិភាពទាំងបួន និងគួរអនុវត្តតាមការសមស្រប ដោយយកចិត្តទុកដាក់គិតគូរលើសមត្ថភាព និងលទ្ធភាព ដោយស្របនឹងច្បាប់ និងបទដ្ឋានគតិយុត្តជាតិ។

**២២**. នៅក្នុងបរិការណ៍ នៃការកើនឡើងជាជាសកលលើការពឹងពាក់អាស្រ័យគ្នាទៅវិញទៅមក កិច្ចសហប្រតិបត្តិការអន្តរជាតិរួម បរិយាកាសអន្តរជាតិអំណោយផល និងមធ្យោបាយនៃការអនុវត្ត គឺត្រូវចាំបាច់ដើម្បីជម្រុញ និងរួមចំណែកដល់ការអភិវឌ្ឍចំណេះដឹង សមត្ថភាព និងការប្រាប់ហេតុផល សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ នៅគ្រប់កម្រិត ជាពិសេសសម្រាប់ប្រទេសដែលកំពុងអភិវឌ្ឍន៍។

## **អាទិភាពទី១**: **ការយល់ដឹងអំពីហានិភ័យគ្រោះមហន្តរាយ**

**២៣**. គោលនយោបាយ និងការអនុវត្ត សម្រាប់ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ គួរផ្អែកលើការយល់ដឹងអំពីហានិភ័យគ្រោះមហន្តរាយគ្រប់ជ្រុងជ្រោយ នៃភាពងាយរងគ្រោះ សមត្ថភាព កម្រិតរងគ្រោះនៃប្រជាជន និងទ្រព្យសម្បត្តិ លក្ខណៈវិនិច្ឆ័យមុខសញ្ញាគ្រោះថ្នាក់ និងបរិស្ថាន។ ចំណេះដឹងបែបនេះ អាចជាថាមពលសម្រាប់ប្រយោជន៍ នៃការប៉ាន់ប្រមាណហានិភ័យគ្រោះមហន្តរាយជាមុនសម្រាប់ការត្រៀមបង្ការ និងការកាត់បន្ថយគ្រោះថ្នាក់ និងសម្រាប់ ការអភិវឌ្ឍ និងការអនុវត្ត ការត្រៀមរៀបចំសមស្រប និងការឆ្លើយតបនឹងគ្រោះមហន្តរាយ ប្រកបដោយប្រសិទ្ធភាព។

## ថ្នាក់ជាតិ និងមូលដ្ឋាន

**២៤**. ដើម្បីសម្រេចគោលបំណងនេះ ជាកាសំខាន់គឺៈ

(**ក**) លើកកម្ពស់ ការប្រមូល ការវិភាគ ការគ្រប់គ្រង និងការប្រើប្រាស់ទិន្នន័យដែលពាក់ព័ន្ធ និងពត៌មានជាក់ស្តែង។ ធានាឲ្យបាននូវការផ្សព្វផ្សាយរបស់ខ្លួន គិតគូរពីតម្រូវការនៃប្រភេទអ្នកប្រើប្រាស់ផ្សេងៗគ្នាតាមការសមស្រប។

(**ខ**) លើកទឹកចិត្តដល់ការប្រើប្រាស់ និងការពង្រឹងមូលដ្ឋានថ្នាក់ក្រោម និងការប៉ាន់ប្រមាណហានិភ័យគ្រោះមហន្តរាយយូៗម្តង នូវភាពងាយរងគ្រោះ សមត្ថភាព កម្រិតរងគ្រោះ លក្ខណៈវិនិច្ឆ័យរបស់មុខសញ្ញាគ្រោះថ្នាក់ និងដែលអាចធ្វើបានលំដាប់ឥទ្ធិពលរបស់វាទាក់ទងសង្គមនៃកម្រិត និងទំហំអវកាស មកលើប្រព័ន្ធអេកូឡូស៊ី ស្របជាមួយនឹងកាលៈទេសៈជាតិ។

(**គ**) អភិវឌ្ឍន៍ ធ្វើបច្ចុប្បន្នភាពយូៗម្តង និងធ្វើការផ្សព្វផ្សាយ ព័ត៌មានហានិភ័យគ្រោះមហន្តរាយ ផ្អែកតាមទីតាំងសមស្រប រួមទាំងផែនទីហានិភ័យ ដល់អ្នកធ្វើសេចក្តីសម្រេចចិត្តជាសាធារណៈទូទៅ និងសហគមន៍ មានហានិភ័យឆ្ពោះទៅគ្រោះមហន្តរាយ ក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានផ្អែកភូមិសាស្រ្ត តាមទម្រង់សមស្រប។

(**ឃ**) វាយតម្លៃ កត់ត្រា ចែករំលែក មានលក្ខណៈជាប្រព័ន្ធ និងពន្យល់ជាសាធារណៈ ការបាត់បង់ដោយគ្រោះមហន្តរាយ និងការយល់ដឹងអំពីសេដ្ឋកិច្ច សង្គម សុខាភិបាល អប់រំ ផលប៉ះពាល់បរិស្ថាន និងកេរតំណែលវប្បធម៌ តាមការសមស្របក្នុងបរិការណ៍នៃព្រឹត្តិការណ៍ជាក់លាក់ មុខសញ្ញាគ្រោះថ្នាក់ កម្រិតរងគ្រោះ និងព័ត៌មានភាពងាយរងគ្រោះ។

(ខ) ធ្វើមិនឲ្យឆាប់ភ័យខ្លាច ពីកម្រិតរងគ្រោះមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ ហានិភ័យគ្រោះមហន្តរាយ និងការបាត់បង់ ព័ត៌មានមិនគាប់ចិត្ត ដែលអាចទទួលបានដោយសេរី និងរកបានសមស្រប។

(ច) លើកកម្ពស់ដល់ការទទួលបាននូវទិន្នន័យដែលអាចជឿទុកចិត្តបាន តាមពេលវេលា ពិតប្រាកដ ធ្វើការប្រើប្រាស់ព័ត៌មានអវកាសតាមទីតាំងកំណត់ រួមទាំងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) និងប្រើប្រាស់ព័ត៌មាន ការបង្កើតថ្មីនៃបច្ចេកវិទ្យាគមនាគមន៍ ដើម្បីធ្វើឲ្យប្រសើរឡើងនូវឧបករណ៍វាស់វែង និងការប្រមូល ការវិភាគ និងការផ្សព្វផ្សាយទិន្នន័យ។

(ឆ) កសាងចំណេះដឹងរបស់មន្ត្រីរដ្ឋាភិបាលនៅគ្រប់កម្រិត សង្គមស៊ីវិល សហគមន៍ និងអ្នកស្ម័គ្រចិត្ត ក៏ដូចជាវិស័យឯកជន តាមរយៈការចែករំលែកបទពិសោធន៍ មេរៀនទទួលបាន ការអនុវត្តន៍ល្អៗ ការបណ្តុះបណ្តាលនិងការអប់រំ ស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ រួមទាំងការប្រើប្រាស់យន្តការ នៃការបណ្តុះបណ្តាល និងការអប់រំដែលមានស្រាប់ និងការរៀនសូត្រពីគ្នាទៅវិញទៅមក។

(ជ) លើកកម្ពស់ និងធ្វើឲ្យកាន់តែប្រសើរនូវកិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការក្នុងចំណោមសហគមន៍វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាគ្រប់ភាគីពាក់ព័ន្ធ និងអ្នកធ្វើគោលនយោបាយ ដើម្បីជួយសម្រួលដល់គោលនយោបាយទាក់ទងទៅនឹងផ្នែកវិទ្យាសាស្ត្រ សម្រាប់ធ្វើសេចក្តីសម្រេចចិត្ត ក្នុងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព។

(ឈ) ធានាដល់ការប្រើប្រាស់តាមបែបប្រពៃណី ជនជាតិដើមភាគតិច ចំណេះដឹង និងការអនុវត្តរបស់មូលដ្ឋាន តាមការសមស្រប ដើម្បីបំពេញចំណេះដឹងផ្នែកវិទ្យាសាស្ត្រក្នុងការប៉ាន់ប្រមាណហានិភ័យគ្រោះមហន្តរាយ ការអភិវឌ្ឍ និងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងកម្មវិធី នៃវិស័យជាក់លាក់ ជាមួយនឹងវិធីសាស្ត្រ នៃវិស័យទាក់ទិន ដែលបានរៀបចំតាមមូលដ្ឋាន និងតាមបរិការណ៍។

(ញ) ពង្រឹងសមត្ថភាពបច្ចេកទេស និងវិទ្យាសាស្ត្រ ដើម្បីជាទុនក្នុងការពង្រឹងចំណេះដឹងដែលមានស្រាប់ និងដើម្បីអភិវឌ្ឍ អនុវត្តន៍វិធីសាស្ត្រ និងគម្រូ ក្នុងការប៉ាន់ប្រមាណហានិភ័យគ្រោះមហន្តរាយ ភាពងាយរងគ្រោះ និងកម្រិតរងគ្រោះពីគ្រប់មុខសញ្ញាគ្រោះថ្នាក់។

(ង)  លើកកម្ពស់ការវិនិយោគនៅក្នុងការអភិវឌ្ឍ បច្ចេកវិទ្យា និង នវកម្ម (ការបង្កើតថ្មី) សម្រាប់រយៈពេលវែង ពហុមុខសញ្ញាគ្រោះថ្នាក់ និងស្រាវជ្រាវរកគំនាស់ដំណោះស្រាយ ក្នុងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ដើម្បីដោះស្រាយការខ្វះខាត ឧបសគ្គ ការពឹងពាក់គ្នាទៅវិញទៅមក និងសង្គម សេដ្ឋកិច្ច អប់រំ និងការប្រឈមទៅនឹងបរិស្ថាន និងហានិភ័យគ្រោះមហន្តរាយ។

(ច)  លើកកម្ពស់ ការដាក់បញ្ចូលចំណេះដឹងហានិភ័យគ្រោះមហន្តរាយ រួមទាំងការត្រៀមបង្ការគ្រោះមហន្តរាយ ការកាត់បន្ថយគ្រោះថ្នាក់ ការត្រៀមរៀបចំ ការឆ្លើយតប ការស្តារឡើងវិញ និងការធ្វើឲ្យប្រសើរឡើងវិញ ទៅក្នុងការអប់រំជាប្រព័ន្ធ និងក្រៅប្រព័ន្ធ ក៏ដូចជានៅក្នុងការអប់រំពលរដ្ឋនៅគ្រប់កម្រិត និងនៅក្នុងការអប់រំ និងបណ្តុះបណ្តាជំនាញវិជ្ជាជីវៈ។

(ឆ)  លើកកម្ពស់យុទ្ធសាស្ត្រជាតិដើម្បីពង្រឹងការអប់រំជាសាធារណៈ និងការយល់ដឹងក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ រួមទាំងព័ត៌មាន និងចំណេះដឹងហានិភ័យគ្រោះមហន្តរាយ តាមរយៈយុទ្ធនាការ ប្រព័ន្ធផ្សព្វផ្សាយសង្គម និងការកៀរគរសហគមន៍ ដោយគិតគូរដល់អ្នកចូលរួម និងតម្រូវការជាក់លាក់របស់ពួកគេ។

(ជ)  ប្រើប្រាស់ ព័ត៌មានហានិភ័យគ្រប់ជ្រុងជ្រោយនៃភាពងាយរងគ្រោះ សមត្ថភាព និងកម្រិតរងគ្រោះនៃប្រជាជន សហគមន៍ ប្រទេស និងទ្រព្យសម្បត្តិ ក៏ដូចជាលក្ខណៈវិនិច្ឆ័យរបស់មុខសញ្ញាគ្រោះថ្នាក់ ដើម្បីអភិវឌ្ឍន៍ និងអនុវត្តន៍គោលនយោបាយ កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

(ឈ)  បង្កើនកិច្ចសហការ ក្នុងចំណោមប្រជាជននៅមូលដ្ឋាន ដើម្បីផ្សព្វផ្សាយព័ត៌មានហានិភ័យគ្រោះមហន្តរាយ តាមរយៈការចូលរួមរបស់អង្គការចាត់តាំងសហគមន៍មូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាល។

## ថ្នាក់សកល និងតំបន់

**២៥.**  ដើម្បីសម្រេចគោលបំណងនេះជាការសំខាន់គឺ៖

(ក)  បង្កើនការអភិវឌ្ឍ និងផ្សព្វផ្សាយអំពីវិធីសាស្ត្រ និងឧបករណ៍វិទ្យាសាស្ត្រ ជាមូលដ្ឋានដើម្បីកត់ត្រា និងចែករំលែកការបាត់បង់ដោយគ្រោះមហន្តរាយ ទិន្នន័យ និងស្ថិតិបំបែកដែលពាក់ព័ន្ធ ដើម្បីពង្រឹងម៉ូដែលនៃហានិភ័យគ្រោះមហន្តរាយ ការប៉ាន់ប្រមាណ ការកំណត់ផែនទី ការត្រួតពិនិត្យតាមដាន និងប្រព័ន្ធប្រកាសឲ្យដឹងមុនអំពីពហុមុខសញ្ញាគ្រោះថ្នាក់។

(ខ) លើកកម្ពស់ការធ្វើអង្កេតទូលំទូលាយ អំពីពហុមុខសញ្ញាគ្រោះថ្នាក់ នៃហានិភ័យគ្រោះមហន្តរាយ និងការអភិវឌ្ឍ ការប៉ាន់ប្រមាណ និងផែនទីហានិភ័យគ្រោះមហន្តរាយនៅថ្នាក់តំបន់ រួមទាំងសេណារីយ៉ូនៃការប្រែប្រួលអាកាសធាតុ។

(គ) លើកកម្ពស់ និងបង្កើន តាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ រួមទាំងការផ្ទេរបច្ចេកវិទ្យា ទទួលបានដើម្បីចែករំលែក និងការប្រើប្រាស់ទិន្នន័យ និងព័ត៌មានមិនឲ្យឆាប់ភ័យខ្លាច តាមការសមស្រប នូវការទំនាក់ទំនង និងបច្ចេកវិទ្យាអវកាស និងផ្នែកភូមិសាស្ត្រជាមូលដ្ឋាន និងសេវាកម្មពាក់ព័ន្ធដទៃទៀត។ រក្សា និងពង្រឹងការសង្កេតព្រឹត្តិការណ៍នៃផែនដី និងអាកាសធាតុពីចម្ងាយ។ ពង្រឹងការប្រើប្រាស់ ប្រព័ន្ធឃោសនា រួមទាំងប្រព័ន្ធឃោសនាសង្គម ប្រព័ន្ធឃោសនាបែបប្រពៃណី ទិន្នន័យធំ និងបណ្តាញទូរស័ព្ទចល័ត ដើម្បីគាំទ្រដល់វិធានការជាតិសម្រាប់ការប្រាស្រ័យទាក់ទងលើផ្នែកហានិភ័យគ្រោះមហន្តរាយ ដោយជោគជ័យតាមការសមស្រប និងអនុលោមតាមច្បាប់ជាតិ។

(ឃ) លើកកម្ពស់ដល់កិច្ចខិតខំប្រឹងប្រែងជាទូទៅ ក្នុងភាពជាដៃគូជាមួយសហគមន៍វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា បណ្ឌិតសភា និងវិស័យឯកជន ដើម្បីបង្កើត ផ្សព្វផ្សាយ និងចែករំលែកការអនុវត្តល្អៗជាលក្ខណៈអន្តរជាតិ។

(ង) គាំទ្រដល់ការអភិវឌ្ឍ ប្រព័ន្ធ និងសេវាកម្ម ប្រើប្រាស់ងាយស្រួល នៅមូលដ្ឋានថ្នាក់ជាតិ តំបន់ និងសកលលោក សម្រាប់ការផ្លាស់ប្តូរព័ត៌មានស្តីពីការអនុវត្តន៍ល្អៗ មានគុណប្រយោជន៍ និងងាយស្រួលប្រើប្រាស់បច្ចេកវិទ្យា នៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងមេរៀនបទពិសោធន៍ អំពីគោលនយោបាយ ផែនការ និងវិធានការសម្រាប់ការកាត់បន្ថយគ្រោះមហន្តរាយ។

(ច) បង្កើតយុទ្ធនាការប្រកបដោយប្រសិទ្ធិភាព នៅថ្នាក់សកល និងតំបន់ ដែលជាឧបករណ៍ សម្រាប់លើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការអប់រំ ការកសាងលើអ្វីដែលមានស្រាប់ (ឧទាហរណ៍ "*សុវត្ថិភាពសាលារៀន និងមន្ទីរពេទ្យមួយលាន*" *ការផ្តួចផ្តើម* "*ធ្វើឲ្យទីក្រុងមានភាពធន់: ទីក្រុងរបស់ខ្ញុំបានត្រៀមខ្លួនជាស្រេច*" យុទ្ធនាការរបស់អង្គការសហប្រជាជាតិ ក្នុងការផ្តល់រង្វាន់សាសាកាវ៉ា សម្រាប់ការងារកាត់បន្ថយគ្រោះមហន្តរាយ និងទិវាអន្តរជាតិប្រចាំឆ្នាំ របស់អង្គការសហប្រជាជាតិសម្រាប់ការកាត់បន្ថយគ្រោះមហន្តរាយ) ដើម្បីលើកកម្ពស់វប្បធម៌ នៃការត្រៀមបង្ការគ្រោះមហន្តរាយ ភាពធន់ និងការទទួលខុសត្រូវរបស់ប្រជា

ពលរដ្ឋ ធ្វើឲ្យមានការយល់ដឹងអំពីហានិភ័យគ្រោះមហន្តរាយ ជួយគាំទ្រដល់ការរៀនសូត្រពីគ្នាទៅវិញទៅមក និងការចែករំលែក បទពិសោធន៍។ លើកទឹកចិត្តដល់ភាគីពាក់ព័ន្ធ វិស័យសាធារណៈនិងវិស័យឯកជន ឲ្យចូលរួមយ៉ាងសកម្ម ក្នុងការផ្តួចផ្តើមណាមួយ និងបង្កើតអ្វីមួយថ្មីនៅមូលដ្ឋាន ថ្នាក់ជាតិ តំបន់ និងសកល។

(**ឆ**) បង្កើនការងារវិទ្យាសាស្ត្រ និងបច្ចេកទេស ស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការកៀរគរបស់ខ្លួន តាមរយៈការសម្របសម្រួល នៃបណ្តាញ និងស្ថាប័នស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រដែលមានស្រាប់ នៅគ្រប់ថ្នាក់ និងតំបន់ទាំងអស់ ជាមួយនឹងការគាំទ្ររបស់ក្រុមផ្តល់ប្រឹក្សាបច្ចេកទេស និងវិទ្យាសាស្ត្រនៃយុទ្ធសាស្ត្រអន្តរជាតិដើម្បីកាត់បន្ថយគ្រោះមហន្តរាយ នៃអង្គការសហប្រជាជាតិដើម្បីៈ ពង្រឹងភស្តុតាងមូលដ្ឋាន ក្នុងការគាំទ្រដល់ការអនុវត្តន៍ក្របខ័ណ្ឌនេះ។ លើកកំពស់ការស្រាវជ្រាវវិទ្យាសាស្ត្រនៃលំនាំហានិភ័យគ្រោះមហន្តរាយ មូលហេតុនិងផលប៉ះពាល់។ ផ្សព្វផ្សាយព័ត៌មានហានិភ័យ ជាមួយនឹងការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មានផ្នែកភូមិសាស្ត្រឲ្យបានល្អ។ ផ្តល់នូវការណែនាំស្តីពីវិធីសាស្ត្រ និងស្តង់ដាសម្រាប់ការប៉ាន់ប្រមាណហានិភ័យ ម៉ដែលហានិភ័យគ្រោះមហន្តរាយ និងការប្រើប្រាស់ទិន្នន័យ។ កំណត់បញ្ជាក់ការខ្វះខាត នៃការស្រាវជ្រាវ និងបច្ចេកវិទ្យា និងលើកជាអនុសាសន៍សម្រាប់ ស្រាវជ្រាវកន្លែងអាទិភាពក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ លើកកម្ពស់និងគាំទ្រ ដល់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដែលមានស្រាប់ និងអាចប្រើប្រាស់បាន ក្នុងការធ្វើសេចក្តី សម្រេចចិត្ត។ ចូលរួមចំណែកក្នុងការធ្វើបច្ចុប្បន្នភាពនូវបច្ចេកស័ព្ទ ស្តីពីការកាត់បន្ថយហានិភ័យ គ្រោះមហន្តរាយឆ្នាំ២០០៩ របស់យុទ្ធសាស្ត្រអន្តរជាតិដើម្បីកាត់បន្ថយគ្រោះមហន្តរាយនៃអង្គការសហប្រជាជាតិ។ ប្រើប្រាស់ឯកសារត្រួតពិនិត្យក្រោយគ្រោះមហន្តរាយ ដែលជាកាលានុវត្តភាពដើម្បីបង្កើនការរៀនសូត្រ គោលនយោបាយសាធារណៈ និងការផ្សព្វផ្សាយ ការសិក្សា។

(**ជ**) លើកទឹកចិត្ត ភាពប្រើប្រាស់បាននៃច្បាប់ រក្សាសិទ្ធិ និងប្រកាសនីយប័ត្រ មានស្រាប់ តាមរយៈការចរចាសម្បទាន តាមការសមស្រប។

(**ឈ**) បង្កើនការគាំទ្រដល់ នវកម្ម (ការបង្កើតថ្មី) និងបច្ចេកវិទ្យា សម្រាប់រយៈពេលវែង ពហុមុខ សញ្ញាគ្រោះថ្នាក់ និងគំនាស់ដំណោះស្រាយនៃការស្រាវជ្រាវ និងការអភិវឌ្ឍ ក្នុងការគ្រប់គ្រង ហានិភ័យគ្រោះមហន្តរាយ។

## អាទិភាពទី២: ការពង្រឹងអភិបាលកិច្ចហានិភ័យគ្រោះមហន្តរាយ ដើម្បីគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ

**២៦**. អភិបាលកិច្ចហានិភ័យគ្រោះមហន្តរាយ នៅថ្នាក់ជាតិ តំបន់ និងសកល គឺមានសារៈសំខាន់ណាស់ សម្រាប់ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ ចក្ខុវិស័យ ផែនការ សមត្ថកិច្ច ការណែនាំ និងការសម្របសម្រួល ច្បាស់លាស់ នៅក្នុងវិស័យទាក់ទិន ក៏ដូចជាការចូលរួមរបស់ភាគីពាក់ព័ន្ធគឺជាការចាំបាច់។ ពង្រឹងអភិបាលកិច្ចហានិភ័យគ្រោះមហន្តរាយ សម្រាប់ការត្រៀមបង្ការ ការកាត់បន្ថយគ្រោះថ្នាក់ ការត្រៀមរៀបចំ ការឆ្លើយតប ការស្តារឡើងវិញ និងការកសាងឡើងវិញ គឺជាការចាំបាច់ ដែលជម្រុញដល់កិច្ចសហការ និងភាពជាដៃគូទូទាំងស្ថាប័ន និងយន្តការសម្រាប់ការអនុវត្តឧបករណ៍ពាក់ព័ន្ធទៅនឹងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

### ថ្នាក់ជាតិ និងមូលដ្ឋាន

**២៧**. ដើម្បីសម្រេចគោលបំណងនេះជាការសំខាន់គឺ៖

(**ក**) បញ្ជ្រាប និងសមាហរណកម្ម ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទៅក្នុង និងនៅគ្រប់វិស័យ។ ត្រួតពិនិត្យឡើងវិញ និងលើកកម្ពស់ការទំនាក់ទំនង និងការអភិវឌ្ឍបន្ថែមទៀតតាមការសមស្រប ទៅនឹងក្របខ័ណ្ឌច្បាប់ បទដ្ឋានគតិយុត្ត និងគោលនយោបាយរបស់ជាតិ និងមូលដ្ឋាន ដែលកំណត់ពីតួនាទី និងការទទួលខុសត្រូវដឹកនាំលើវិស័យសាធារណៈ និងឯកជនដើម្បី: (i) ដោះស្រាយហានិភ័យគ្រោះមហន្តរាយជាសាធារណៈ គ្រប់គ្រង ឬបទបញ្ជា សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធ។ (ii) លើកកម្ពស់ និងផ្តល់នូវការលើកទឹកចិត្ត ដែលពាក់ព័ន្ធទៅនឹងសកម្មភាពរបស់បុគ្គល គ្រួសារ សហគមន៍ និងអាជីវកម្ម។ (iii) បង្កើននូវយន្តការ និងការផ្តួចផ្តើមពាក់ព័ន្ធដល់តម្លាភាពហានិភ័យគ្រោះមហន្តរាយ ដែលអាចរួមទាំងការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ លើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការផ្តួចផ្តើមការបណ្តុះបណ្តាលតម្រូវការរបាយការណ៍ និងវិធានការផ្នែកច្បាប់និងរដ្ឋបាល និង (iv) រៀបចំឲ្យមានរចនាសម្ព័ន្ធសម្របសម្រួល និងចាត់តាំង។

(**ខ**) អនុម័ត និងអនុវត្តផែនការ យុទ្ធសាស្ត្រកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅថ្នាក់ជាតិ និងមូលដ្ឋាន គ្រប់រយៈពេលខុសគ្នា ជាមួយនឹងគោលដៅ សូចនាករ និងកាលកំណត់ ក្នុងគោលបំណងការពារនូវការកកើតឡើងនៃហានិភ័យ ការកាត់បន្ថយហានិភ័យដែលមានស្រាប់ និងពង្រឹងភាពធន់ដល់ផ្នែកសេដ្ឋកិច្ច សង្គម សុខភាព និងបរិស្ថាន។

(ឝ) ធ្វើការប៉ាន់ប្រមាណ លើសមត្ថភាពនៃការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ បច្ចេកទេស រដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីដោះស្រាយនូវហានិភ័យដែលបានកំណត់នៅថ្នាក់ជាតិ និងមូលដ្ឋាន។

(ឃ) លើកទឹកចិត្តដល់ការបង្កើតនូវយន្តការចាំបាច់ និងការលើកទឹកចិត្តដើម្បីធានាបាននូវកម្រិតខ្ពស់ នៃការអនុវត្តបទប្បញ្ញត្តិនៃច្បាប់ និងបទដ្ឋានគតិយុត្ត ស្តីពីការលើកកម្ពស់សុវត្ថិភាព ដែលមានស្រាប់ រួមទាំងដោះស្រាយការប្រើប្រាស់ដីធ្លី និងផែនការរៀបចំទីក្រុង ច្បាប់សាងសង់ ការគ្រប់គ្រងបរិស្ថាននិងធនធាន ស្តង់ដាសុវត្ថិភាពនិងសុខភាព និងធ្វើបច្ចុប្បន្នភាពដល់ពួកគេ នៅតាមទីកន្លែងដែលត្រូវការចាំបាច់ ដើម្បីធានាឲ្យបានគ្រប់គ្រាន់ដល់ការផ្តោតទៅលើការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។

(ង) បង្កើត និងពង្រឹងយន្តការតាមការសមស្រប ដើម្បីបន្តតាមដាន ប៉ាន់ប្រមាណតាមដំណាក់កាល និងរាយការណ៍ជាសាធារណៈស្តីពីការរីកចម្រើនលើផែនការរបស់ថ្នាក់ជាតិ និងមូលដ្ឋាន។ លើកកម្ពស់ការត្រួតពិនិត្យជាសាធារណៈ និងការលើកទឹកចិត្តដល់ស្ថាប័នពិភាក្សាដេញដោល រួមទាំងសមាជិកសភា និងមន្ត្រីពាក់ព័ន្ធ ស្តីពីរបាយការណ៍រីកចម្រើននៃផែនការថ្នាក់ជាតិ និងមូលដ្ឋាន សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

(ច) ចាត់តាំង ផ្តល់តួនាទីច្បាស់លាស់ និងភារកិច្ចសមស្រប ដល់តំណាងសហគមន៍ក្នុងស្ថាប័នគ្រប់គ្រងគ្រោះមហន្តរាយ ដំណើរការ និងការធ្វើសេចក្តីសម្រេចតាមរយៈក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធ។ ធ្វើការពិគ្រោះយោបល់ជាសាធារណៈ និងសហគមន៍ដ៏ទូលំទូលាយ អំឡុងពេលការរៀបចំច្បាប់ និងបទដ្ឋានគិតយុត្ត ដើម្បីគាំទ្រដល់ការអនុវត្តន៍របស់ពួកគេ។

(ឆ) បង្កើត និងពង្រឹងវេទិកាសម្របសម្រួលរបស់រដ្ឋាភិបាល ដែលមានសមាសភាពពីភាគីពាក់ព័ន្ធនៅថ្នាក់ជាតិ និងមូលដ្ឋាន ដូចជាវេទិកាជាតិ និងមូលដ្ឋាន សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងជ្រើសតាំង*មន្ត្រីបង្គោលថ្នាក់ជាតិមួយរូប* សម្រាប់អនុវត្តក្របខ័ណ្ឌក្រោយឆ្នាំ២០១៥។ វាមានសារៈសំខាន់ណាស់ សម្រាប់យន្តការបែបនេះ ដែលមានគ្រឹះរឹងមាំនៅក្នុងក្របខ័ណ្ឌស្ថាប័នជាតិ ដោយបានប្រគល់ការទទួលខុសត្រូវ និងសិទ្ធិអំណាចយ៉ាងច្បាស់លាស់ ដើម្បីកំណត់អត្តសញ្ញាណហានិភ័យគ្រោះមហន្តរាយ តាមវិស័យ និងពហុវិស័យ កសាងការយល់ដឹង និងចំណេះដឹងអំពីហានិភ័យគ្រោះមហន្តរាយ តាមរយៈការចែករំលែក និងផ្សព្វផ្សាយព័ត៌មាន និងទិន្នន័យហានិភ័យគ្រោះមហន្តរាយមិនឲ្យឆាប់ភ័យខ្លាច ចូលរួមចំណែក និងសម្របសម្រួលរបាយការណ៍ ស្តីពីហានិភ័យគ្រោះមហន្តរាយ នៅថ្នាក់ ជាតិ

និងមូលដ្ឋាន សម្របសម្រួលការធ្វើយុទ្ធនាការលើកកម្ពស់ការយល់ដឹងជាសាធារណៈ អំពីហានិភ័យគ្រោះមហន្តរាយ សម្រួល និងគាំទ្រដល់កិច្ចសហប្រតិបត្តិការ នៃពហុវិស័យនៅមូលដ្ឋាន (ឧទាហរណ៍៖ ក្នុងចំណោមរដ្ឋាភិបាលមូលដ្ឋាន) ចូលរួមចំណែកកំណត់ និងរាយការណ៍អំពីផែនការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ នៅថ្នាក់ជាតិ និងមូលដ្ឋាន និងរាល់គោលនយោបាយ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងគ្រោះមហន្តរាយ។ ការទទួលខុសត្រូវទាំងនេះគួរតែត្រូវបានបង្កើតឡើងតាមរយៈច្បាប់ បទដ្ឋានគតិយុត្ត ស្តង់ដា និងនីតិវិធី។

(**ង**) ផ្តល់សិទ្ធិអំណាចដល់អាជ្ញាធរមូលដ្ឋានសមស្រប តាមរយៈមធ្យោបាយច្បាប់ និងហិរញ្ញវត្ថុ ដើម្បីធ្វើការ និងសម្របសម្រួលជាមួយសង្គមស៊ីវិល សហគមន៍ និងជនជាតិដើមភាគតិច និងទេសន្តរប្រវេសន៍ ក្នុងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅមូលដ្ឋាន។

(**ឈ**) លើកទឹកចិត្តដល់សមាជិកសភា ដើម្បីជួយគាំទ្រដល់ការអនុវត្តន៍ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ តាមរយៈការអភិវឌ្ឍថ្មី ឬវិសោធនកម្មច្បាប់ពាក់ព័ន្ធ និងវិភាជន៍ថវិកា។

(**ញ**) លើកកម្ពស់ការអភិវឌ្ឍស្តង់ដាគុណភាព ដូចជាការបញ្ជាក់ និងផ្តល់រង្វាន់សម្រាប់ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ដោយមានការចូលរួមពីវិស័យឯកជន សង្គមស៊ីវិល សមាគមជំនាញវិជ្ជាជីវៈ អង្គការវិទ្យាសាស្ត្រ និងអង្គការសហប្រជាជាតិ។

(**ដ**) កសាងគោលនយោបាយសាធារណៈ ដែលអាចអនុវត្តបាន សំដៅដោះស្រាយបញ្ហា នៃការត្រៀមបង្ការ ឬការផ្លាស់ប្តូរទីលំនៅ តាមដែលអាចធ្វើទៅបាន នៃការតាំងទីលំនៅរបស់ប្រជាជននៅក្នុងតំបន់ហានិភ័យគ្រោះមហន្តរាយ ដែលស្ថិតនៅក្រោមច្បាប់ជាតិ និងប្រព័ន្ធច្បាប់។

## ថ្នាក់សកល និងតំបន់

**២៨**. ដើម្បីសម្រេចគោលបំណងនេះជាការសំខាន់គឺ៖

(**ក**) សកម្មភាពបង្ហាញផ្លូវនៅថ្នាក់តំបន់ តាមរយៈយុទ្ធសាស្ត្រ និងយន្តការថ្នាក់តំបន់ និងអនុតំបន់ដែលបានព្រមព្រៀង សម្រាប់កិច្ចសហប្រតិបត្តិការក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ សមស្របតាមក្របខ័ណ្ឌនេះ ដើម្បីជម្រុញ ផែនការឲ្យមានប្រសិទ្ធភាពបន្ថែមទៀត រៀបចំបង្កើតប្រព័ន្ធព័ត៌មានរួម ផ្លាស់ប្តូរការអនុវត្តល្អៗ និងកម្មវិធីសម្រាប់កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍសមត្ថភាព ដោយឡែកដើម្បីគាំទ្ររួមគ្នា និងដោះស្រាយហានិភ័យគ្រោះមហន្តរាយឆ្លងដែន។

(ខ) ជម្រុញឲ្យមានការរីកចម្រើន ដល់កិច្ចសហការ យន្តការ តំបន់ និងសកលលោក ដែលទាក់ទិន និងស្ថាប័នសម្រាប់អនុវត្ត និងភាពផ្សារភ្ជាប់គ្នា និងឧបករណ៍ដែលពាក់ព័ន្ធ ក្នុងការការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដូចជាការប្រែប្រួលអាកាសធាតុ ជីវចម្រុះ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ការលុបបំបាត់ភាពក្រីក្រ បរិស្ថាន កសិកម្ម សុខភាព ស្បៀង និងអាហារូបត្ថម្ភ និងការងារដទៃទៀត តាមការសមស្រប។

(គ) ចូលរួមយ៉ាងសកម្មភាព ក្នុងវេទិកាសកលសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ វេទិកាថ្នាក់តំបន់ និងអនុតំបន់សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងវេទិកាទៅតាមប្រធានបទ ដើម្បីបង្កើតភាពជាដៃគូ ប៉ាន់ប្រមាណជាទៀងទាត់ពីវឌ្ឍនភាពនៃការអនុវត្ត ចែករំលែកនូវការអនុវត្ត និងការយល់ដឹងអំពីហានិភ័យគ្រោះមហន្តរាយ គោលនយោបាយ កម្មវិធី និងការវិនិយោគ រួមទាំងការងារអភិវឌ្ឍន៍ និងអាកាសធាតុ តាមការសមស្រប ក៏ដូចជាការលើកកម្ពស់ ការធ្វើសមាហរណកម្មការងារគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយទៅក្នុងវិស័យពាក់ព័ន្ធផ្សេងទៀត។ អង្គការអន្តររដ្ឋាភិបាលថ្នាក់តំបន់ គួរដើរតួនាទីយ៉ាងសំខាន់ក្នុងវេទិកាថ្នាក់តំបន់សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

(ឃ) លើកកម្ពស់កិច្ចសហប្រតិបត្តិការឆ្លងដែន ដើម្បីអនុញ្ញាតឲ្យគោលនយោបាយ និងផែនការ សម្រាប់ការអនុវត្ត វិធីសាស្ត្រប្រព័ន្ធអេកូមូលដ្ឋាន ដោយមានការចែករំលែកធនធាន ដូចជានៅតាមអាងទន្លេ និងតាមបណ្តោយឆ្នេរសមុទ្រ ការកសាងភាពធន់ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ រួមទាំងជំងឺរាតត្បាត និងហានិភ័យនៃការផ្លាស់ទីលំនៅ។

(ង) លើកកម្ពស់ការរៀនសូត្រពីគ្នាទៅវិញទៅមក និងការផ្លាស់ប្តូរនៃការអនុវត្តល្អ និងព័ត៌មានតាមរយៈ ការស្ម័គ្រចិត្ត មិត្តភក្តិផ្តួចផ្តើមដោយខ្លួនឯង និងក្នុងចំណោមប្រទេស ដែលមានចំណាប់អារម្មណ៍។

(ច) លើកកម្ពស់ការពង្រឹង នូវយន្តការស្ម័គ្រចិត្តរបស់អន្តរជាតិ តាមការសមស្រប សម្រាប់ត្រួតពិនិត្យតាមដាន និងប៉ាន់ប្រមាណហានិភ័យគ្រោះមហន្តរាយ រួមទាំងទិន្នន័យ និងព័ត៌មានដែលពាក់ព័ន្ធ ដែលបានទទួលផលប្រយោជន៍ពីបទពិសោធនៃត្រួតពិនិត្យតាមដានរបស់ក្របខ័ណ្ឌការងារសកម្មភាពហ្យូហ្គោ។ យន្តការដែលបានលើកឡើងនេះ អាចជម្រុញដល់ការផ្លាស់ប្តូរព័ត៌មានដែលមិនឲ្យឆាប់ភ័យខ្លាច អំពីហានិភ័យគ្រោះមហន្តរាយ ទៅដល់ស្ថាប័ន

រដ្ឋាភិបាល ថ្នាក់ជាតិ និងភាគីពាក់ព័ន្ធ ក្នុងផលប្រយោជន៍នៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ប្រកបដោយនិរន្តរភាព។

## អាទិភាពទី៣: ការវិនិយោគ នៅក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ សម្រាប់ភាពធន់

**២៩**. ការវិនិយោគ របស់ផ្នែកសាធារណៈ និងឯកជន ក្នុងការត្រៀមបង្ការ និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ តាមរយៈវិធានការបែបរចនាសម្ព័ន្ធ និងបែបមិនមែន រចនាសម្ព័ន្ធគឺមានសារៈសំខាន់ ដើម្បីបង្កើនសេដ្ឋកិច្ច សង្គម សុខភាព និងវប្បធម៌នៃភាពធន់ របស់ប្រជាជន សហគមន៍ ប្រទេស និងទ្រព្យសម្បត្តិរបស់ពួកគេ ក៏ដូចជាបរិស្ថានផងដែរ។ ទាំងនេះអាចជាចលករ នៃរបកគំហើញថ្មី កំណើន និងការបង្កើតការងារ។ វិធានការបែបនេះគឺមានគុណប្រយោជន៍ និងជាឧបករណ៍សង្គ្រោះជីវិត ត្រៀមបង្ការ និងកាត់បន្ថយការបាត់បង់ និងធានាបាននូវការស្តារឡើងវិញ ការធ្វើឲ្យប្រសើរឡើងវិញ និងកសាងឡើងវិញ ប្រកបដោយប្រសិទ្ធិភាព។

### ថ្នាក់ជាតិ និងមូលដ្ឋាន

**៣០**. ដើម្បីសម្រេចគោលបំណងនេះជាការសំខាន់គឺ៖

(**ក**) វិភាជន៍ធនធានចាំបាច់ រួមទាំងហិរញ្ញវត្ថុ និងភស្តុភា សមស្របនៅតាមរដ្ឋបាលគ្រប់កម្រិត សម្រាប់ការអភិវឌ្ឍ និងការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រកាត់បន្ថយគ្រោះមហន្តរាយ ផែនការ ច្បាប់ និងបទដ្ឋានគតិយុត្ត នៅគ្រប់វិស័យដែលពាក់ព័ន្ធទាំងអស់។

(**ខ**) លើកកម្ពស់យន្តការ សម្រាប់ការផ្ទេរហានិភ័យគ្រោះមហន្តរាយ និងការធានារ៉ាប់រង ការចែករំលែកហានិភ័យ និងការរក្សាទុក និងការការពារហិរញ្ញវត្ថុ តាមការសមស្របសម្រាប់ទាំងការវិនិយោគក្នុងផ្នែកឯកជន និងសាធារណៈ ដើម្បីកាត់បន្ថយផលប៉ះពាល់ដោយគ្រោះមហន្តរាយលើផ្នែកហិរញ្ញវត្ថុរបស់រដ្ឋាភិបាល និងសង្គម នៅតាមតំបន់ទីក្រុង និងជនបទ។

(**គ**) ពង្រឹងការវិនិយោគ សម្រាប់ភាពធន់គ្រោះមហន្តរាយសមស្របដល់ផ្នែកឯកជន និងសាធារណៈ ជាពិសេសតាមរយៈ៖ បែបរចនាសម្ព័ន្ធ បែបមិនមែនរចនាសម្ព័ន្ធ វិធានការត្រៀមបង្ការ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយជាមធ្យោបាយសំខាន់ ជាពិសេសនៅតាមសាលារៀន មន្ទីរពេទ្យ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការស្ថាបនាឲ្យប្រសើរជាងមុន ចាប់តាំងពីការចាប់ផ្តើម ដើម្បីទ្រាំទ្រនឹងមុខសញ្ញាគ្រោះថ្នាក់ តាមរយៈការគូប្លង់ និងការសាងសង់ត្រឹមត្រូវ រួមទាំងការប្រើប្រាស់គោលការណ៍នៃគម្រោងការណ៍សកល សម្ភារៈសំណង់មាន

ស្តង់ដា ការជួសជុល និងការស្តាបនាឡើងវិញ ការអប់រំនូវវប្បធម៌នៃការថែទាំ យកចិត្តទុកដាក់លើផ្នែកសេដ្ឋកិច្ច សង្គម រចនាសម្ព័ន្ធ បច្ចេកវិទ្យា និងប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន។

(**ឃ**) ការពារ ឬគាំទ្រដល់ការការពារ ស្ថាប័នវប្បធម៌ប្រមូលផ្តុំ និងទីតាំងប្រវត្តិសាស្ត្រផ្សេងទៀត បេតិកភណ្ឌវប្បធម៌ និងសាសនាដែលជាការចាប់អារម្មណ៍។

(**ង**) លើកកម្ពស់ភាពធន់ហានិភ័យគ្រោះមហន្តរាយ នៅតាមទីកន្លែងធ្វើការងារ តាមរយៈវិធានការ បែបរចនាសម្ព័ន្ធ និងបែបមិនមែនរចនាសម្ព័ន្ធ។

(**ច**) លើកកម្ពស់ការបញ្ជ្រាប នៃការប៉ាន់ប្រមាណហានិភ័យគ្រោះមហន្តរាយ ទៅក្នុងការអភិវឌ្ឍ និងការអនុវត្តគោលនយោបាយដីធ្លី រួមទាំងផែនការទីក្រុង ការប៉ាន់ប្រមាណលើការថយចុះគុណភាពដី លំនៅស្ថានមិនរៀបរយ និងមិនអចិន្ត្រៃយ៍ និងការប្រើប្រាស់គោលការណ៍ណែនាំ និងឧបករណ៍តាមដានដំណឹង ពីប្រជាសាស្ត្រ និងការប្រែប្រួលបរិស្ថាន ដែលគិត ទុកជាមុន។

(**ឆ**) លើកកម្ពស់ការបញ្ជ្រាប នៃការប៉ាន់ប្រមាណហានិភ័យគ្រោះមហន្តរាយ ការរៀបចំ និងការគ្រប់គ្រង ទៅក្នុងផែនការអភិវឌ្ឍជនបទ ក្នុងចំណោមនោះមាន ភ្នំ ទន្លេ តំបន់ លិចទឹកនៅតាមតំបន់ទំនាបឆ្នេរ ដីគោក ដីសើម និងតំបន់ដទៃទៀតដែលងាយនឹងគ្រោះរាំងស្ងួត និងទឹកជំនន់ ក្នុងនោះក៏មានការកំណត់តំបន់សុវត្ថិភាពសម្រាប់ ប្រជាជនទទួលបានក្រោយការព្រមព្រៀង នៅពេលដូចគ្នានេះដែរ ក៏មានការរក្សាមុខងាររបស់ប្រព័ន្ធអេកូ ដែលជួយដល់ការកាត់បន្ថយហានិភ័យ។

(**ជ**) លើកទឹកចិត្តដល់ការពិនិត្យឡើងវិញ នូវអ្វីដែលមានស្រាប់ ឬការអភិវឌ្ឍថ្មីនូវច្បាប់សាងសង់ ស្តង់ដា ការស្តារឡើងវិញ និងការកសាងឡើងវិញ នៅថ្នាក់ជាតិ ឬមូលដ្ឋានតាមការសមស្រប ជាមួយនឹងគោលបំណង ដើម្បីធ្វើឲ្យពួកគេកាន់តែអាចអនុវត្តបានក្នុងបរិបទមូលដ្ឋាន ដោយឡែកក្នុងការតាំងទីលំនៅមិនរៀបរយ និងបន្ទាប់បន្សំរបស់មនុស្ស និងការពង្រឹង សមត្ថភាពដើម្បី អនុវត្ត អង្កេត និងពង្រឹងច្បាប់នោះ តាមរយៈវិធីសាស្ត្រសម ស្របដោយគិតគូរ អំពីការជម្រុញដល់ភាពធន់របស់រចនាសម្ព័ន្ធទៅនឹងគ្រោះមហន្តរាយ។

(**ឈ**) បង្កើនភាពធន់ របស់ប្រព័ន្ធសុខាភិបាលថ្នាក់ជាតិ រួមទាំងសមាហរណកម្មការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ទៅក្នុងការថែទាំសុខភាព បឋម មធ្យម និងឧត្តមជាពិសេសនៅមូលដ្ឋាន។ ការអភិវឌ្ឍសមត្ថភាពមន្ត្រីសុខាភិបាល ដល់ការយល់ដឹងពីហានិភ័យគ្រោះមហន្តរាយ ប្រើប្រាស់ និងអនុវត្តវិធីសាស្ត្រ នៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅក្នុងការងារសុខាភិបាល។ លើកកម្ពស់ និងពង្រឹង ការបណ្តុះបណ្តាសមត្ថភាព នៅនឹងកន្លែង

នូវមុខវិជ្ជាពេទ្យ នៃគ្រោះមហន្តរាយ។ គាំទ្រ និងបណ្តុះបណ្តាលក្រុមសុខភាពសហគមន៍លើវិធីសាស្ត្រ កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ក្នុងកម្មវិធីសុខភាព ដោយសហការជាមួយវិស័យដទៃទៀត ក៏ដូចជាការអនុវត្តបទដ្ឋានគតិយុត្តសុខភាពអន្តរជាតិ (ឆ្នាំ២០០៥) នៃអង្គការសុខភាពពិភពលោក។

(ញ) ពង្រឹងគម្រោងការណ៍ និងការអនុវត្ត ដែលរាប់បញ្ចូលគោលនយោបាយ និងយន្តការសុវត្ថិភាពសំណាញ់សង្គម តាមរយៈការចូលរួមរបស់សហគមន៍ សមាហរណកម្មកម្មវិធីលើកកម្ពស់ជីវភាពរស់នៅ និងការទទួលបាននូវសេវាថែទាំសុខភាពមូលដ្ឋាន រួមទាំងមាតុភាព ទារកទើបនឹងកើត និង សុខភាពកុមារ ផ្នែកផ្លូវភេទ និងសុខភាពបន្តពូជ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ លំនៅស្ថាន និងការអប់រំ ឈានឆ្ពោះទៅការបំបាត់ភាពក្រីក្រ ដើម្បីស្វែងរកដំណោះស្រាយរយៈពេលវែង នៅដំណាក់កាលក្រោយគ្រោះមហន្តរាយ ផ្តល់សិទ្ធិអំណាច និង ជួយដល់ជនទន់ខ្សោយ ដែលរងផលប៉ះពាល់ដោយគ្រោះមហន្តរាយ។

(ដ) អ្នកដែលមានការគំរាមកំហែងដល់ជីវិត និងជំងឺរ៉ាំរ៉ៃ ដោយសារតែមានតម្រូវការជាពិសេសរបស់ពួកគេ គួរត្រូវបានដាក់បញ្ចូលនៅក្នុងគម្រោងការណ៍នៃគោលនយោបាយ និងផែនការ ដើម្បីគ្រប់គ្រងហានិភ័យរបស់ពួកគេ នៅមុនពេល ក្នុងពេល និងក្រោយពេលគ្រោះមហន្តរាយ រួមទាំងលទ្ធភាពទទួលបានសេវាសង្គ្រោះជីវិត។

(ឋ) លើកទឹកចិត្ត ដល់ការអនុម័តគោលនយោបាយ និងកម្មវិធី ក្នុងការដោះស្រាយការចល័តមនុស្ស ដែលរងផលប៉ះពាល់ដោយគ្រោះមហន្តរាយ ដើម្បីពង្រឹងភាពធន់ របស់ប្រជាជន និងសហគមន៍ទទួលរងផលប៉ះពាល់ តាមកាលៈទេសៈ និងច្បាប់របស់ជាតិនិមួយៗ។

(ឌ) លើកកម្ពស់ ការធ្វើសមាហរណកម្ម ការពិនិត្យពិច្ច័យ និងវិធានការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ទៅក្នុងឧបករណ៍ហិរញ្ញវត្ថុ និងសារពើពន្ធ តាមការសមស្រប។

(ឍ) ពង្រឹងការប្រើប្រាស់ប្រកបដោយនិរន្តរភាព និងការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ី និងអនុវត្ត ធ្វើសមាហរណកម្មគ្រងធនធានធម្មជាតិ និងបរិស្ថាន ជួយគាំទ្រការរួមបញ្ចូលទៅក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

(ណ) បង្កើនភាពធន់របស់ធុរកិច្ចការការពាររបររកទទួលទាននិងទ្រព្យសកម្មផលិតកម្មនៅទូទាំងខ្សែសង្វាក់ផ្គត់ផ្គង់។ធានាឲ្យបាននូវនិរន្តរភាព នៃការផ្តល់សេវា និងការធ្វើសមាហរណកម្ម ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ទៅក្នុងម៉ូដែល និងកិច្ចការជំនួញ។

(ឆ) ពង្រឹងការការពាររបររកទទួលទាន និងទ្រព្យសកម្មផលិតកម្ម ដូចជា សត្វចិញ្ចឹម សត្វពាហនៈជាកម្លាំងអូសទាញ ឧបករណ៍ និងគ្រាប់ពូជ។

(ជ) ជម្រុញ និងសមាហរណកម្មវិធីសាស្ត្រនៃការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ នៅទូទាំងឧស្សាហកម្មទេសចរណ៍ដែលតែងតែពឹងផ្អែកជាញឹកញាប់ធ្ងន់ទៅលើវិស័យ ទេសចរណ៍ ដែលជាគំនាស់សេដ្ឋកិច្ចដ៏សំខាន់។

## ថ្នាក់សកល និងតំបន់

**៣១**. ដើម្បីសម្រេចគោលបំណងនេះជាការសំខាន់គឺៈ

(ក) លើកកម្ពស់ ភាពមិនរបេះចេញពីគ្នា ប្រព័ន្ធទាក់ទងនៃវិស័យ និងអង្គការពាក់ព័ន្ធ ដើម្បីអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅក្នុង គោល នយោបាយ ផែនការ កម្មវិធី និងដំណើរការរបស់ពួកគេ។

(ខ) លើកកម្ពស់ការអភិវឌ្ឍ និងការពង្រឹង នៃការផ្ទេរហានិភ័យគ្រោះមហន្តរាយ និង ការចែករំលែកយន្តការ និងឧបករណ៍ក្នុងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយដៃគូ នៅក្នុងសហគមន៍អន្តរជាតិ ធុរកិច្ច ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងគ្រប់ភាគីពាក់ព័ន្ធផ្សេងទៀត។

(គ) លើកកម្ពស់កិច្ចសហប្រតិបត្តិការ រវាងបណ្ឌិតសភា អង្គភាព និងបណ្តាញស្រាវជ្រាវវិទ្យាសាស្ត្រ និងវិស័យឯកជន ដើម្បីបង្កើតផលិតផល និងសេវាកម្មថ្មី ដើម្បីជួយកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ជាពិសេសភាគីដែលនឹងជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ និងបញ្ហាប្រឈមជាក់លាក់របស់ពួកគេ។

(ឃ) លើកទឹកចិត្តដល់កិច្ចសម្របសម្រួល រវាងស្ថាប័នហិរញ្ញវត្ថុពិភពលោក និងតំបន់ ដោយធ្វើការប៉ាន់ប្រមាណ និងគិតគូរទុកជាមុនពីសក្តានុពលនៃផលប៉ះពាល់លើផ្នែកសេដ្ឋកិច្ច និងសង្គម ដែលបង្កដោយគ្រោះមហន្តរាយ។

(ង) បង្កើនកិច្ចសហប្រតិបត្តិការ រវាងអាជ្ញាធរសុខាភិបាល និងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីពង្រឹងសមត្ថភាពរបស់ប្រទេស សម្រាប់ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ លើផ្នែក សុខភាព ការអនុវត្តបទដ្ឋានគតិយុត្ត សុខភាពអន្តរជាតិ (ឆ្នាំ២០០៥) និងការកសាងប្រព័ន្ធភាពធន់សុខាភិបាល។

(ច) ពង្រឹង និងលើកកម្ពស់កិច្ចសហការ និងការកសាងសមត្ថភាពសម្រាប់ការការពារដល់ទ្រព្យសកម្មផលិតកម្ម រួមមានសត្វចិញ្ចឹម សត្វពាហនៈជាកម្លាំងអូសទាញ ឧបករណ៍ និងគ្រាប់ពូជ។

(**ឆ**) លើកកម្ពស់ និងគាំទ្រដល់ការអភិវឌ្ឍ នៃសំណាញ់សុវត្ថិភាពសង្គមដែលជាវិធានការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដែលបានផ្សារភ្ជាប់ និងសមាហរណកម្មជាមួយនឹងកម្មវិធីលើកកម្ពស់ការប្រកបរបរទទួលទាន ដើម្បីធានាឲ្យបាននូវភាពធន់ទៅនឹងវិបត្តិនៅកម្រិតគ្រួសារ និងសហគមន៍។

(**ជ**) ពង្រឹង និងពង្រីកនូវកិច្ចខិតខំប្រឹងប្រែងរបស់អន្តរជាតិ ក្នុងគោលបំណងលុបបំបាត់ភាពអត់ឃ្លាន និងភាពក្រីក្រ តាមរយៈការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

(**ឈ**) លើកកម្ពស់ និងគាំទ្រដល់កិច្ចសហការគ្នាក្នុងចំណោម ភាគីពាក់ព័ន្ធ ផ្នែកឯកជន និងសាធារណៈ ដើម្បីបង្កើនភាពធន់នៃធុរកិច្ច ទៅនឹងគ្រោះមហន្តរាយ។

## អាទិភាពទី៤: លើកកម្ពស់ ការត្រៀមរៀបចំគ្រោះមហន្តរាយ សម្រាប់ការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និង "ការស្ថាបនាឲ្យប្រសើរជាងមុន" ក្នុងការស្តារឡើងវិញ ការធ្វើឲ្យប្រសើរឡើងវិញ និងការកសាងឡើងវិញ

**៣២**. កំណើនខ្ពស់នៃហានិភ័យគ្រោះមហន្តរាយ រួមទាំងការកើនឡើងនៃប្រជាជន និងទ្រព្យសម្បត្តិដែលងាយទទួលរងផលប៉ះពាល់ រួមផ្សំនឹងមេរៀនបទពិសោធន៍ដែលទទួលបានពីគ្រោះមហន្តរាយពីអតីតកាល បានបង្ហាញពីតម្រូវការ ក្នុងការពង្រឹងការត្រៀមរៀបចំគ្រោះមហន្តរាយបន្ថែមទៀត សម្រាប់ការឆ្លើយតប ការចាត់វិធានការសម្រាប់ព្រឹត្តិការណ៍នៃគ្រោះមហន្តរាយដែលនឹងអាចកើតឡើងនាពេលខាងមុខ សមាហរណកម្មការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទៅក្នុងការត្រៀមរៀបចំសម្រាប់ឆ្លើយតប និងធានាថាសមត្ថភាព ដែលមានស្រាប់ សម្រាប់ការឆ្លើយតប និងការស្តារ ឡើងវិញនៅគ្រប់កម្រិត ប្រកបដោយប្រសិទ្ធភាព។ ផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងជនពិការ ដើម្បីដឹកនាំសាធារណៈជន និងលើកកម្ពស់សមធម៌យេនឌ័រ និងអាចទទួលបាននូវការឆ្លើយតបជាសកល វិធីសាស្ត្រនៃការស្តារឡើងវិញ ការធ្វើឲ្យប្រសើរឡើងវិញ និងការកសាងឡើងវិញ ជាដំណោះស្រាយគន្លឹះ។ គ្រោះមហន្តរាយបានស្រាយបំភ្លឺ ដំណាក់កាលនៃការស្តារឡើងវិញ ការធ្វើឲ្យប្រសើរឡើងវិញ និងការកសាងឡើងវិញ តម្រូវឲ្យមានការត្រៀមគ្រោះមហន្តរាយខាងមុខ នេះគឺជាកាលានុវត្តភាពស្លាប់រស់ ក្នុងការស្ថាបនាឲ្យប្រសើរជាងមុន រួមទាំងតាមរយៈការធ្វើសមាហរណកម្ម ការកាត់ បន្ថយហានិភ័យគ្រោះមហន្តរាយ ទៅក្នុងវិធានការអភិវឌ្ឍនានា និងធ្វើឲ្យប្រទេសជាតិ និងសហគមន៍ធន់ទៅនឹងគ្រោះមហន្តរាយ។

## ថ្នាក់ជាតិ និងមូលដ្ឋាន

**៣៣**. ដើម្បីសម្រេចគោលបំណងនេះជាការសំខាន់គឺៈ

(**ក**) រៀបចំ ឬពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពនូវកម្មវិធី ផែនការ និងគោលនយោបាយ នៃការត្រៀមរៀបចំ និងត្រៀមបម្រុង ដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធ ដោយពិនិត្យពិចារណាលើ សេណារីយ៉ូនៃការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ដោយហានិភ័យគ្រោះមហន្តរាយ និងសម្រួលតាមការសមស្របដល់ការចូលរួមពីគ្រប់វិស័យទាំងអស់ និងគ្រប់ភាគីពាក់ព័ន្ធ។

(**ខ**) វិនិយោគ នៅក្នុងការអភិវឌ្ឍ ការថែទាំ និងការពង្រឹងប្រជាជនជាស្នូល ចំពោះពហុមុខសញ្ញាគ្រោះថ្នាក់ ការព្យាករណ៍ពហុវិស័យ ប្រព័ន្ធប្រកាសឲ្យដឹងមុន និងយន្តការទំនាក់ទំនងគ្រោះអាសន្ន និងហានិភ័យគ្រោះមហន្តរាយ បច្ចេកវិទ្យាសង្គម និងប្រព័ន្ធទូរគមនាគមន៍តាមដានត្រួតពិនិត្យមុខសញ្ញាគ្រោះថ្នាក់ ហើយការអភិវឌ្ឍប្រព័ន្ធបែបនេះតាមរយៈដំណើរនៃការចូលរួម។ ជាចុងក្រោយ វាត្រូវទៅនឹងតម្រូវការរបស់អ្នកប្រើប្រាស់ រួមទាំងតម្រូវការផ្នែកសង្គម និងវប្បធម៌ ជាពិសេសផ្នែកយេនឌ័រ។ លើកកម្ពស់ការអនុវត្តប្រើប្រាស់ឧបករណ៍ និងមធ្យោបាយប្រកាសឲ្យដឹងមុន ដែលមានតម្លៃទាប មានលក្ខណៈសាមញ្ញ និងពង្រីកបណ្តាញ ផ្សព្វផ្សាយសម្រាប់ប្រកាសឲ្យដឹងមុន អំពីព័ត៌មានគ្រោះមហន្តរាយធម្មជាតិ។

(**គ**) លើកកម្ពស់ភាពធន់ លើហេដ្ឋារចនាសម្ព័ន្ធសំខាន់ថ្មី និងមានស្រាប់ រួមទាំងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនតាមផ្លូវទឹក និងទូរគមនាគមន៍ អាគារសិក្សា មន្ទីរពេទ្យ និងមណ្ឌលសុខភាពដទៃទៀត ដើម្បីធានាថាពួកគេមានសុវត្ថិភាព និងប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ក្នុងពេល និងក្រោយពេលគ្រោះមហន្តរាយ ក្នុងការផ្តល់សេវាចាំបាច់ដល់ការជួយសង្គ្រោះជីវិត។

(**ឃ**) បង្កើតមណ្ឌលសហគមន៍ សម្រាប់លើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការស្តុកទុកនៃសម្ភារៈចាំបាច់មួយចំនួន ដើម្បីបម្រើដល់សកម្មភាពជួយសង្គ្រោះ និងផ្តល់ជំនួយសង្គ្រោះ។

(**ង**) អនុម័តលើគោលនយោបាយ និងសកម្មភាពសាធារណៈ ដែលគាំទ្រដល់តួនាទីរបស់អ្នកបម្រើសេវាសាធារណៈ ដើម្បីបង្កើត ឬពង្រឹងយន្តការសម្របសម្រួល មូលនិធិ នីតិវិធីសម្រាប់ការផ្តល់ជំនួយសង្គ្រោះ រៀបចំផែនការ និងត្រៀមសម្រាប់ការស្តារឡើងវិញ និងកសាងឡើងវិញក្រោយគ្រោះមហន្តរាយ។

(ច) បណ្តុះបណ្តាល ដល់កម្លាំងការងារ និងស្ម័គ្រចិត្តដែលមានស្រាប់ ក្នុងការឆ្លើយតបគ្រោះមហន្តរាយ និងពង្រឹងសមត្ថភាពបច្ចេកទេស និងការផ្គត់ផ្គង់ ដើម្បីធានាដល់ការឆ្លើយតបបានល្អប្រសើរក្នុងពេលគ្រោះអាសន្ន។

(ឆ) ធានាបាននូវកិច្ចប្រតិបត្តិការ និងផែនការប្រកបដោយនិរន្តរភាព រួមទាំងការស្តារសេដ្ឋកិច្ច និងសង្គមឡើងវិញ និងការផ្តល់សេវាជាមូលដ្ឋាននៅដំណាក់កាលក្រោយគ្រោះមហន្តរាយ។

(ជ) លើកកម្ពស់ការត្រៀមរៀបចំគ្រោះមហន្តរាយជាទៀងទាត់ ការធ្វើលំហាត់ឆ្លើយតប និងស្តារឡើងវិញ រួមទាំងការធ្វើលំហាត់ជម្លៀស ការបណ្តុះបណ្តាល និងការបង្កើតប្រព័ន្ធគាំទ្រនៅតាមមូលដ្ឋានតំបន់ ដើម្បីធានាដល់ការឆ្លើយតបគ្រោះមហន្តរាយរហ័ស ប្រកបដោយប្រសិទ្ធភាព និងទាក់ទងទៅនឹងការផ្លាស់ទីតាំង ដូចជាការទទួលបានជម្រកសុវត្ថិភាព ការផ្គត់ផ្គង់ស្បៀងអាហារ និងសម្ភារៈសង្គ្រោះចាំបាច់ សមស្របតាមតម្រូវការរបស់មូលដ្ឋាន។

(ឈ) លើកកម្ពស់កិច្ចសហប្រតិបត្តិការ ជាមួយស្ថាប័ននានា អាជ្ញាធរចម្រុះ និងគ្រប់ភាគីពាក់ព័ន្ធនៅគ្រប់កម្រិត រួមទាំងសហគមន៍ និងធុរកិច្ចដែលទទួលរងផលប៉ះពាល់ដោយសារការកសាងឡើងវិញក្រោយគ្រោះមហន្តរាយ មានភាពស្មុគស្មាញ និងចំណាយថ្លៃក្រោមកិច្ចសម្របសម្រួលរបស់អាជ្ញាធរជាតិ។

(ញ) ជម្រុញការដាក់បញ្ចូល ការងារគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ទៅក្នុងដំណើរការនៃការស្តារឡើងវិញ និងការធ្វើឲ្យប្រសើរឡើងវិញ ក្រោយគ្រោះមហន្តរាយ ជួយសម្រួលដល់ការផ្សារភ្ជាប់គ្នា រវាងការផ្តល់ជំនួយសង្គ្រោះ ការស្តារឡើងវិញ និងការអភិវឌ្ឍ។ ប្រើប្រាស់កាលានុវត្តភាព ក្នុងដំណាក់កាលស្តារឡើងវិញ ដើម្បីអភិវឌ្ឍន៍សមត្ថភាព ដែលអាចកាត់បន្ថយហានិភ័យគ្រោះ មហន្តរាយក្នុងរយៈពេលខ្លី មធ្យម និងរយៈពេលវែង តាមរយៈវិធានការនៃការអភិវឌ្ឍមួយ ចំនួនដូចជា ការធ្វើផែនការប្រើប្រាស់ដីធ្លី ការកែលម្អរស្តង់ដារចនាសម្ព័ន្ធ និងចែករំលែក ជំនាញ ចំណេះដឹង ពិនិត្យឡើងវិញក្រោយគ្រោះមហន្តរាយ និងមេរៀនបទពិសោធន៍។ សមាហរណកម្ម នៃការកសាងឡើងវិញក្រោយពីគ្រោះមហន្តរាយ ទៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ប្រកបដោយនិរន្តរភាព នៅតំបន់ដែលរងឥទ្ធិពល។ ប្រការនេះគួរអនុវត្តនៅតាមទីតាំងបណ្តោះអាសន្ន សម្រាប់អ្នកដែលបានជម្លៀសដោយគ្រោះមហន្តរាយ។

(ដ) បង្កើតគោលការណ៍ណែនាំលើការត្រៀមរៀបចំ សម្រាប់ការកសាងឡើងវិញពីគ្រោះមហន្តរាយ ដូចជាធ្វើផែនការប្រើប្រាស់ដីធ្លី និងការកែលម្អរស្តង់ដារចនាសម្ព័ន្ធ ដោយរៀនសូត្រពីកម្មវិធីស្តារឡើងវិញ និងកសាងឡើងវិញ ក្នុងពេលជាងមួយទសវត្សរ៍ចាប់តាំងពី

ការអនុម័តក្របខ័ណ្ឌការងារសកម្មភាពយូហ្គោ (HFA) និងការផ្លាស់ប្តូរបទពិសោធន៍ ចំណេះដឹង និងមេរៀនបទពិសោធន៍។

(**ឋ**) ពិចារណាផ្លាស់ប្តូរទីតាំងអាគារសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធទៅកាន់តំបន់នៅក្រៅជួរហានិភ័យ បើអាចធ្វើទៅបាន នៅក្នុងដំណើរការនៃការកសាងឡើងវិញក្រោយគ្រោះមហន្តរាយ ដោយធ្វើការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធតាមការសមស្រប។

(**ឌ**) ពង្រឹងសមត្ថភាពរបស់អាជ្ញាធរមូលដ្ឋាន ដើម្បីជម្លៀសមនុស្សដែលរស់នៅក្នុងតំបន់ងាយទទួលរងដោយគ្រោះមហន្តរាយ។

(**ឍ**) បង្កើតយន្តការ ចុះបញ្ជី និងកត់ត្រាទិន្នន័យ លើករណីអ្នកស្លាប់បណ្តាលដោយគ្រោះមហន្តរាយ ដើម្បីបង្កើននូវការត្រៀមបង្ការជំងឺ និងការស្លាប់។

(**ណ**) បង្កើនគម្រោងការណ៍ស្តារឡើងវិញ ដើម្បីផ្តល់នូវការគាំទ្រផ្នែកចិត្តសង្គម និងការផ្តល់ សេវាសុខភាពផ្លូវចិត្តសម្រាប់មនុស្សដែលមានតម្រូវការ។

(**ត**) ពិនិត្យឡើងវិញ និងពង្រឹងច្បាប់ជាតិ នីតិវិធីនៃកិច្ចសហប្រតិបត្តិការអន្តរជាតិតាមការសមស្រប ដោយផ្អែកលើគោលការណ៍ណែនាំ សម្រាប់ការជួយសម្រួល និងលិខិតបទដ្ឋានគតិយុត្ត នៃការផ្តល់ជំនួយសង្គ្រោះគ្រោះមហន្តរាយ និងជំនួយអន្តរជាតិបឋមសម្រាប់ការស្តារឡើងវិញ។

## ថ្នាក់សកល និងតំបន់

**៣៤**. ដើម្បីសម្រេចគោលបំណងនេះជាការសំខាន់គឺៈ

(**ក**) អភិវឌ្ឍ និងពង្រឹងតាមការសមស្របដូចជាវិធីសាស្ត្រសម្របសម្រួល និងយន្តការប្រតិបត្តិការថ្នាក់តំបន់ ដើម្បីរៀបចំ និងធានាឲ្យបានរហ័ស និងមានប្រសិទ្ធភាព លើការឆ្លើយតបគ្រោះមហន្តរាយ ក្នុងស្ថានភាពដែលហួសពីសមត្ថភាពរបស់ជាតិ។

(**ខ**) លើកកម្ពស់ការអភិវឌ្ឍ និងឧបករណ៍ផ្សព្វផ្សាយបន្ថែមទៀត ដូចជា ស្តង់ដា លេខកូដ ណែនាំប្រតិបត្តិការ និងឧបករណ៍ណែនាំផ្សេងទៀត ដើម្បីគាំទ្រដល់សកម្មភាពសម្របសម្រួល ត្រៀមរៀបចំ ឆ្លើយតបគ្រោះមហន្តរាយ និងជួយសម្រួលដល់ការចែករំលែក

ព័ត៌មាន អំពីមេរៀនបទពិសោធន៍ ការអនុវត្តន៍ល្អ និងកម្មវិធីកសាងឡើងវិញ ក្រោយគ្រោះមហន្តរាយ។

(ឍ) លើកកម្ពស់ការអភិវឌ្ឍ និងការវិនិយោគបន្ថែមទៀត ប្រកបដោយប្រសិទ្ធភាពលើយន្តការប្រកាសឲ្យដឹងមុន ចំពោះពហុមុខសញ្ញាគ្រោះថ្នាក់ ដែលអាចប្រៀបធៀបបានរវាងថ្នាក់ជាតិ និងតំបន់ នៅតាមកន្លែងពាក់ព័ន្ធ ស្របជាមួយក្របខ័ណ្ឌសកលសម្រាប់សេវាកម្មអាកាសធាតុ និងសម្រួលដល់ការចែករំលែក និងការផ្លាស់ប្តូរព័ត៌មាននៅទូទាំងប្រទេស។

(ឃ) បង្កើនយន្តការអន្តរជាតិ ដូចជាវេទិកាអន្តរជាតិសម្រាប់ការស្តារឡើងវិញ ដើម្បីចែករំលែកបទពិសោធន៍ និងការរៀនសូត្រក្នុងចំណោមប្រទេស និងភាគីពាក់ព័ន្ធទាំងអស់។

(ខ) គាំទ្រតាមការសមស្រប ដល់អង្គភាពពាក់ព័ន្ធនានារបស់អង្គការសហប្រជាជាតិដើម្បីពង្រឹង និងអនុវត្តយន្តការសកល ស្តីពីបញ្ហាជលសាស្ត្រឧត្តុនិយម ក្នុងគោលបំណងលើកកម្ពស់ និងបង្កើនការយល់ដឹង អំពីហានិភ័យគ្រោះមហន្តរាយទាក់ទងនឹងទឹក និងផលប៉ះពាល់មកលើសង្គម និងពន្លឿនយុទ្ធសាស្ត្រ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយតាមសំណើរបស់រដ្ឋ។

(ច) គាំទ្រដល់កិច្ចសហប្រតិបត្តិការថ្នាក់តំបន់ ក្នុងការដោះស្រាយការត្រៀមរៀបចំគ្រោះមហន្តរាយ រួមមានតាមរយៈការធ្វើលំហាត់សមយុទ្ធ និងការហ្វឹកហាត់។

(ឆ) លើកកម្ពស់ពិធីសារថ្នាក់តំបន់ ដើម្បីជួយសម្រួលដល់ការចែករំលែកសមត្ថភាពឆ្លើយតប និងធនធាន អំឡុងពេល និងក្រោយពេលគ្រោះមហន្តរាយ។

(ជ) បណ្តុះបណ្តាល កងកម្លាំង និងអ្នកស្ម័គ្រចិត្ត ដែលមានស្រាប់ក្នុងការឆ្លើយតបគ្រោះមហន្តរាយ។

## V. តួនាទីរបស់ភាគីពាក់ព័ន្ធ

**៣៥.** ខណៈដែលរដ្ឋមានការទទួលខុសត្រូវរួម លើការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយគឺវាត្រូវបានចែករំលែក ការទទួលខុសត្រូវរវាងរដ្ឋាភិបាល និងភាគីពាក់ព័ន្ធនានា។ ជាពិសេសភាគីពាក់ព័ន្ធមិនមែនជារដ្ឋ ដើរតួនាទីយ៉ាងសំខាន់ដូចជាការផ្តល់ការគាំទ្រដល់រដ្ឋ អនុលោមតាមគោលនយោបាយ ច្បាប់ និងបទដ្ឋានគតិយុត្តជាតិ ក្នុងការអនុវត្តន៍ក្របខ័ណ្ឌ នៅមូលដ្ឋានថ្នាក់ជាតិ តំបន់ និងសកល។ ការប្តេជ្ញាចិត្ត សុឆន្ទៈ ចំណេះដឹង បទពិសោធន៍ និងធនធានរបស់ពួកគាត់ នឹងជាតម្រូវការ។

៣៦.	ពេលមានការកំណត់ពីតួនាទី និងការទទួលខុសត្រូវជាក់លាក់សម្រាប់ភាគីអ្នកពាក់ព័ន្ធ នៅពេលដែលមានការកសាងឯកសារអន្តរជាតិពាក់ព័ន្ធដែលមានស្រាប់ រដ្ឋគួរលើក ទឹកចិត្ត ដល់សកម្មភាពមួយចំនួន ដែលជាផ្នែកមួយរបស់ភាគីពាក់ព័ន្ធផ្នែកសាធារណៈ និងឯក ជន ទាំងអស់ៈ

(**ក**) អង្គការសង្គមស៊ីវិល អ្នកស្ម័គ្រចិត្ត រៀបចំបង្កើតការងារស្ម័គ្រចិត្ត និងអង្គការ មូលដ្ឋានសហគមន៍ដើម្បីៈ ចូលរួម សហការជាមួយស្ថាប័នសាធារណៈ ក្នុងចំណោមការងារ នោះ គឺផ្តល់ចំណេះដឹងជាក់លាក់ និងគោលការណ៍ណែនាំជាក់ស្តែង ក្នុងបរិបទ នៃការអភិវឌ្ឍ និងការអនុវត្តក្របខ័ណ្ឌនិយាម ស្តង់ដា និងផែនការសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះ មហន្តរាយ។ ចូលរួមក្នុងការអនុវត្តផែនការ និងយុទ្ធសាស្រ្តមូលដ្ឋាន ថ្នាក់ជាតិ តំបន់ និង សកល។ រួមចំណែក និងគាំទ្រដល់ការយល់ដឹងជាសាធារណៈ វប្បធម៌នៃការត្រៀមបង្ការ និង ការអប់រំ ស្តីពីហានិភ័យគ្រោះមហន្តរាយ។ ការគាំទ្រផ្នែកផ្លូវច្បាប់ សម្រាប់ការធន់ទ្រាំរបស់ សហគមន៍ រួមទាំងសង្គមទាំងមូល ក្នុងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ដែលនឹង ពង្រឹងកម្លាំងរួមរបស់ក្រុមតាមការសមស្រប។ នៅលើចំណុចនេះ វាគួរតែត្រូវបានកត់សម្គាល់ថាៈ

(i) ស្រ្តី និងការចូលរួមរបស់ពួកគាត់ មានសារៈសំខាន់ក្នុងការគ្រប់គ្រងហានិភ័យគ្រោះ មហន្តរាយ និងគម្រោងការណ៍ ប្រកបដោយប្រសិទ្ធភាព។ ធនធាន និងការអនុវត្តគោល នយោបាយ ផែនការ កម្មវិធីយេនឌ័រ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ វិធានការ កសាង សមត្ថភាព ចាំបាច់ត្រូវចាត់ការឲ្យបានសមស្រប ដើម្បីផ្តល់អំណាចដល់ស្រ្តីសម្រាប់ ការត្រៀមរៀបចំ ក៏ដូចជាការកសាងសមត្ថភាពរបស់ពួកគាត់ លើជម្រើសនៃមធ្យោបាយចញ្ចឹម ជីវិតក្នុង ស្ថានភាពក្រោយគ្រោះមហន្តរាយ។

(ii) កុមារនិងយុវជន គឺជាភ្នាក់ងារនៃការផ្លាស់ប្តូរ និងគួរត្រូវបានផ្តល់កន្លែង និងគំរូបែបបទ ដើម្បីរួមចំណែកដល់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ អនុលោមតាមបទដ្ឋានគតិ យុត្ត ការអនុវត្ត និងកម្មវិធីអប់រំជាតិ។

(iii) ជនពិការ និងអង្គការរបស់ពួកគាត់ មានសារៈសំខាន់ក្នុងការប៉ាន់ប្រមាណហានិភ័យ គ្រោះមហន្តរាយ គម្រោងការណ៍ និងការអនុវត្តផែនការ ដែលបានដាក់ចេញតាមតម្រូវការ ជាក់លាក់ ការពិចារណា ក្នុងចំណោមការងារ និងគោលការណ៍នៃគម្រោងការណ៍សកល។

(iv) មនុស្សវ័យចំណាស់ មានចំណេះដឹង ជំនាញច្រើនឆ្នាំ និងប្រាជ្ញា គឺជាទ្រព្យសម្បត្តិដ៏មានតម្លៃ ក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងពួកគេគួរត្រូវបានរួមបញ្ចូលនៅក្នុងការតាក់តែង គោលនយោបាយ ផែនការ និងយន្តការ រួមទាំងការប្រកាសឲ្យដឹងមុន។

(v) ជនជាតិដើមភាគតិច តាមរយៈបទពិសោធន៍ និងចំណេះដឹងប្រពៃណីរបស់ពួកគេ នឹងផ្តល់នូវការរួមចំណែកដ៏សំខាន់ដល់ការអភិវឌ្ឍន៍ និងការអនុវត្តផែនការ និងយន្តការរួមទាំង ការប្រកាសឲ្យដឹងមុន។

(vi) ជនប្រវេសន្ត ក៏រួមចំណែកដល់ភាពធន់របស់សហគមន៍ និងសង្គម និងចំណេះដឹងជំនាញ និងសមត្ថភាពរបស់ពួកគេ អាចមានប្រយោជន៍ នៅក្នុងការតាក់តែង និងការអនុវត្តការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

(ខ) បណ្ឌិតសភា វិទ្យាសាស្ត្រ អង្គភាពស្រាវជ្រាវ និងបណ្តាញ៖ ផ្តោតសំខាន់លើកត្តាហានិភ័យគ្រោះមហន្តរាយ និងសេណារីយ៉ូ រួមទាំងហានិភ័យគ្រោះមហន្តរាយកំពុងកើតឡើងក្នុងរយៈពេលមធ្យម និងរយៈពេលវែង។ បង្កើនការស្រាវជ្រាវ សម្រាប់កម្មវិធី នៅមូលដ្ឋានថ្នាក់ជាតិ និងតំបន់។ គាំទ្រដល់សកម្មភាពរបស់មូលដ្ឋានសហគមន៍ អាជ្ញាធរ និងការងារពាក់ព័ន្ធរួមរវាង គោលនយោបាយ និងវិទ្យាសាស្ត្រសម្រាប់ការសម្រេចចិត្ត។

(គ) ធុរកិច្ច សមាគមជំនាញវិជ្ជាជីវៈ និងស្ថាប័នហិរញ្ញវត្ថុវិស័យឯកជន រួមទាំងនិយ័តករហិរញ្ញវត្ថុ និងស្ថាប័នគណនេយ្យ ក៏ដូចជាមូលនិធិមនុស្សធម៌ ដើម្បី៖ សមាហរណកម្មការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ រួមទាំងនិរន្តរភាព ពាណិជ្ជកម្ម ទៅក្នុងម៉ូដែលអាជីវកម្ម និង ការអនុវត្តន៍ តាមរយៈការវិនិយោគលើព័ត៌មាន ហានិភ័យគ្រោះមហន្តរាយជាពិសេស សហគ្រាសកម្រិត មីក្រូ តូច និងមធ្យម។ ចូលរួមក្នុងការលើកកម្ពស់ការយល់ដឹងនិងការបណ្តុះបណ្តាលដល់បុគ្គលិក និងអតិថិជនរបស់ពួកគេ។ ចូលរួមគាំទ្រដល់ការស្រាវជ្រាវនិងនវកម្ម (ការបង្កើតថ្មី) ក៏ដូចជាការអភិវឌ្ឍន៍បច្ចេកវិទ្យា សម្រាប់ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។ ការចែករំលែក និងផ្សព្វផ្សាយចំណេះដឹង ការអនុវត្ត និងទិន្នន័យមូលដ្ឋាន។ ចូលរួមយ៉ាងសកម្ម តាមការសមស្រប ក្រោមការណែនាំពីវិស័យសាធារណៈ ក្នុងការអភិវឌ្ឍក្របខ័ណ្ឌបទដ្ឋាន និងស្តង់ដាបច្ចេកទេស ដែលដាក់បញ្ចូលទៅក្នុងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។

(ឃ) ប្រព័ន្ធផ្សព្វផ្សាយ៖ មានតួនាទីយ៉ាងសកម្មរួមទាំងនៅមូលដ្ឋាន ថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ក្នុងការរួមចំណែកដល់ការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការផ្សព្វផ្សាយអំពីហានិភ័យគ្រោះមហន្តរាយជាមូលដ្ឋាន មុខសញ្ញាគ្រោះថ្នាក់ និងព័ត៌មានគ្រោះមហន្តរាយប្រកបដោយភាពត្រឹមត្រូវ រួមទាំងគ្រោះមហន្តរាយទ្រង់ទ្រាយតូច សាមញ្ញ តម្លាភាព ងាយស្រួលយល់ និងអាចទទួលយកបាន ក្នុងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយ អាជ្ញាធរជាតិ។ អនុម័តគោលនយោបាយការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយជាក់លាក់។ គាំទ្រតាមការសមស្របដល់ប្រព័ន្ធប្រកាសឲ្យដឹងមុន និងវិធានការការពារសង្គ្រោះជីវិត បំផុសវប្បធម៌ត្រៀមបង្ការ និងការចូលរួមខ្លាំងក្លារបស់សហគមន៍ ក្នុងយុទ្ធនាការនៃការអប់រំជាសាធារណៈប្រកបដោយនិរន្តរភាព និងការពិគ្រោះយោបល់ជាសាធារណៈ នៅគ្រប់កម្រិត នៃសង្គមស្របតាមការអនុវត្ត របស់ថ្នាក់ជាតិ។

**៣៧**. យោងតាមសេចក្ដីសម្រេចមហាសន្និបាតអង្គសហប្រជាជាតិ ៦៨/២១១ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ ការប្ដេជ្ញាចិត្តដោយគ្រប់ភាគីពាក់ព័ន្ធ គឺមានសារៈសំខាន់ក្នុងការកំណត់ពីបែបបទ នៃកិច្ចសហប្រតិបត្តិការ និងអនុវត្តក្របខ័ណ្ឌនេះ។ ការប្ដេជ្ញាចិត្តទាំងនោះ គួរមានភាពជាក់លាក់ និងភ្ជាប់ជាមួយពេលវេលា ដើម្បីគាំទ្រដល់ការអភិវឌ្ឍ ក្នុងភាពជាដៃគូនៅមូលដ្ឋាន ថ្នាក់ជាតិ តំបន់ និងសកល និងការអនុវត្ត ផែនការយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យគ្រោះមហន្តរាយរបស់មូលដ្ឋាន និងថ្នាក់ជាតិ។ គ្រប់ភាគីពាក់ព័ន្ធ ត្រូវបានលើកទឹកចិត្តក្នុងការផ្សព្វផ្សាយនូវការប្ដេជ្ញាចិត្តរបស់ពួកគេ និងបំពេញដល់ការគាំទ្ររបស់ពួកគេ ក្នុងការអនុវត្តក្របខ័ណ្ឌ ឬផែនការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅមូលដ្ឋាន និងថ្នាក់ជាតិតាមរយៈគេហទំព័ររបស់យុទ្ធសាស្ត្រអន្តរជាតិ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយសហប្រជាជាតិ (UNISDR) ។

## VI. កិច្ចសហប្រតិបត្តិការអន្តរជាតិ និងភាពជាដៃគូជាសកល

### ការពិចារណាទូទៅ

**៣៨**. ចំពោះភាពខុសគ្នានៃសមត្ថភាពរបស់គេ ដែលមានក៏ដូចជាការតភ្ជាប់គ្នារវាងកម្រិតនៃការគាំទ្រដែលបានផ្តល់ទៅឲ្យពួកគេ និងទំហំដែលពួកគេនឹងអាចអនុវត្តក្របខ័ណ្ឌបច្ចុប្បន្ននេះ ប្រទេសកំពុងអភិវឌ្ឍន៍តម្រូវឲ្យបង្កើនការផ្តល់មធ្យោបាយសម្រាប់អនុវត្ត រួមទាំងធនធានគ្រប់គ្រាន់ និរន្តរភាព និងទាន់ពេលវេលា តាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ និងភាពជាដៃគូសកលសម្រាប់ការអភិវឌ្ឍ និងបន្តការគាំទ្ររបស់អន្តរជាតិ ដើម្បីពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

៣៩. កិច្ចសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយរួមទាំងប្រភពធនធាន និងធាតុសំខាន់ខុសៗគ្នា ក្នុងការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

៤០. ក្នុងការដោះស្រាយភាពខុសគ្នានៃសេដ្ឋកិច្ច ភាពខុសគ្នា នៃនវកម្ម (ការបង្កើតថ្មី) បច្ចេកវិទ្យា និងសមត្ថភាពស្រាវជ្រាវ នៅក្នុងចំណោមបណ្តាប្រទេស គឺវាមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីបង្កើនការផ្ទេរបច្ចេកវិទ្យា ពាក់ព័ន្ធនឹងដំណើរការ នៃសមត្ថភាពសម្រួលដល់លំហូរនូវបំណិនប្រសប់ ចំណេះដឹង គំនិតយោបល់ ជំនាញ និងបច្ចេកវិទ្យា ពីប្រទេសអភិវឌ្ឍន៍ទៅប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការអនុវត្តន៍ក្របខ័ណ្ឌបច្ចុប្បន្ននេះ។

៤១. ប្រទេសកំពុងអភិវឌ្ឍន៍ដែលងាយទទួលរងគ្រោះដោយ គ្រោះមហន្តរាយ ជាពិសេសប្រទេសមានការអភិវឌ្ឍតិចតួច រដ្ឋដែនកោះតូចៗកំពុងអភិវឌ្ឍន៍ ប្រទេសមិនជាប់ឆ្នេរសមុទ្រកំពុងអភិវឌ្ឍន៍ និងប្រទេសអាហ្វ្រិក ក៏ដូចជាបណ្តាប្រទេសដែលមានប្រាក់ចំណូលមធ្យមដែលប្រឈមមុខនឹងបញ្ហា ជាពិសេស ធានាដល់ការយកចិត្តទុកដាក់ជាពិសេស ដោយពនិត្យឃើញថាភាពងាយរងគ្រោះ និងហានិភ័យខ្ពស់របស់ពួកគេ ជាញឹកញាប់វាលើសពីសមត្ថភាពរបស់ពួកគេក្នុងការឆ្លើយតប និងការស្តារឡើងវិញ ទៅនឹងគ្រោះមហន្តរាយ។ ភាពងាយរងគ្រោះបែបនេះតម្រូវឲ្យមានការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិជាបន្ទាន់ និងធានាដល់ភាពជាដៃគូពិតប្រាកដ និងយូរអង្វែងនៅថ្នាក់តំបន់និងអន្តរជាតិ ដើម្បីគាំទ្រដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការអនុវត្តក្របខ័ណ្ឌនេះ អនុលោមតាមអាទិភាពនៅថ្នាក់ជាតិ និងតម្រូវការរបស់ពួកគេ។ ការយកចិត្តទុកដាក់ស្រដៀងគ្នា និងជំនួយសមស្រប គួរត្រូវបានពង្រីកទៅកាន់ប្រទេសផ្សេងទៀតដែលងាយទទួលរងគ្រោះដោយគ្រោះមហន្តរាយ ដែលមានលក្ខណៈពិសេស ដូចជាបណ្តាប្រទេសប្រជុំកោះ ក៏ដូចជាប្រទេសដែលមានឆ្នេរសមុទ្រដ៏ធំទូលាយ។

៤២. គ្រោះមហន្តរាយអាចប៉ះពាល់មិនស្មើគ្នា ដល់រដ្ឋដែនកោះតូចៗកំពុងអភិវឌ្ឍន៍ ដោយសារតែភាពងាយរងគ្រោះជាពិសេស និងដោយទំហំរបស់ពួកគេ។ ផលប៉ះពាល់បង្កដោយគ្រោះមហន្តរាយ មួយចំនួនបានកើនឡើងយ៉ាងខ្លាំង និងធ្វើឲ្យកាន់តែធ្ងន់ធ្ងរឡើងដោយសារការការប្រែប្រួលអាកាសធាតុ និងរារាំងដល់ការរីកចម្រើនរបស់ខ្លួនឆ្ពោះទៅរកការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។ ចំពោះករណីពិសេស នៃរដ្ឋដែនកោះតូចៗកំពុងអភិវឌ្ឍន៍ មានតម្រូវការចាំបាច់ ក្នុងការកសាងភាពធន់ និងផ្តល់ការគាំទ្រជាពិសេសតាមរយៈ ការអនុវត្តលទ្ធផល

SIDS បង្កើនល្បឿនបែបបទនៃសកម្មភាព (SAMOA) ផ្លូវឆ្លងកាត់[១១] នៅក្នុងតំបន់នៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនេះ។

៤៣. បណ្តាប្រទេសអាហ្វ្រិក នៅបន្តជួបប្រទះនឹងបញ្ហាប្រឈមមុខមួយចំនួន ដែលទាក់ទងទៅនឹងគ្រោះមហន្តរាយ និងការកើនឡើងនៃហានិភ័យ រួមទាំងបញ្ហាដែលទាក់ទងទៅនឹងការបង្កើនភាពធន់ នៃហេដ្ឋារចនាសម្ព័ន្ធ សុខភាព និងការចិញ្ចឹមជីវិត។ បញ្ហាប្រឈមទាំងនេះតម្រូវឲ្យបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ និងផ្តល់ការគាំទ្រគ្រប់គ្រាន់ដល់បណ្តាប្រទេសអាហ្វ្រិក ដើម្បីអនុញ្ញាតឲ្យមានការអនុវត្តក្របខ័ណ្ឌនេះ។

៤៤. កិច្ចសហប្រតិបត្តិការ ខាងជើង-ខាងត្បូង បំពេញដោយ ខាងត្បូង-ខាងត្បូង និងកិច្ចសហប្រតិបត្តិការត្រីកោណ បានបង្ហាញឲ្យឃើញជាគន្លឹះក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងតម្រូវឲ្យពង្រឹងកិច្ចសហប្រតិបត្តិការបន្ថែមទៀត នៅតំបន់ទាំងពីរ។ ភាពជាដៃគូដើរតួនាទីយ៉ាងសំខាន់បន្ថែមទៀត ដោយរក្សាសក្តានុពលពេញលេញរបស់បណ្តាប្រទេស

[១១] សេចក្តីសម្រេចអង្គការសហប្រជាជាតិ ៦៩/១៥, ឧបសម្ព័ន្ធ

និងគាំទ្រសមត្ថភាពជាតិរបស់គេ ក្នុងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ និងការលើកកម្ពស់សុខភាពសង្គម និងសេដ្ឋកិច្ច សុខុមាលភាពរបស់បុគ្គល សហគមន៍ និងប្រទេស។

៤៥. កិច្ចខិតខំប្រឹងប្រែងដោយប្រទេសកំពុងអភិវឌ្ឍន៍ ដែលផ្តល់ដល់ ខាងត្បូង-ខាងត្បូង និងកិច្ចសហប្រតិបត្តិការត្រីកោណ មិនគួរកាត់បន្ថយកិច្ចសហប្រតិបត្តិការខាងជើង-ខាងត្បូង ពីប្រទេសអភិវឌ្ឍន៍ ដូចដែលពួកគេបំពេញលើកិច្ចសហប្រតិបត្តិការខាងជើង-ខាងត្បូង។

៤៦. ហិរញ្ញវត្ថុអាចមកពីប្រភពនៃអន្តរជាតិខុសៗគ្នា ការផ្ទេររបស់ផ្នែកសាធារណៈ និងឯកជន នូវបច្ចេកវិទ្យាទំនើបប្រកបដោយបរិស្ថានល្អ ដែលអាចជឿទុកចិត្តបាន និងមានតំលៃសមរម្យ លើល័ក្ខខ័ណ្ឌសម្បទាន និងការអនុគ្រោះ ដែលជាកិច្ចព្រមព្រៀងគ្នាទៅវិញទៅមក។ ជំនួយដល់ការកសាងសមត្ថភាពសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។ ស្ថាប័នមានសមត្ថកិច្ច និងបរិស្ថាន នយោបាយនៅគ្រប់កម្រិត គឺជាមធ្យោបាយដ៏សំខាន់ ក្នុងការកាត់បន្ថយហានិភ័យគ្រោះ មហន្តរាយ។

## មធ្យោបាយនៃការអនុវត្ត

៤៧. ដើម្បីសម្រេចគោលបំណងនេះជាការសំខាន់គឺ៖

(**ក**) ការបញ្ជាក់ឡើងវិញ ពីប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវផ្តល់ការសម្របសម្រួលឲ្យបានប្រសើរឡើង និរន្តភាព និងការគាំទ្រជាអន្តរជាតិឲ្យបានគ្រប់គ្រាន់ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ជាពិសេសសម្រាប់ប្រទេសដែលមានការអភិវឌ្ឍតិចតួច រដ្ឋដែនកោះតូចៗកំពុងការអភិវឌ្ឍន៍ បណ្តាប្រទេសមិនជាប់ឆ្នេរសមុទ្រកំពុងអភិវឌ្ឍន៍ និងប្រទេសអាហ្វ្រិក ក៏ដូចជាប្រទេសមានប្រាក់ចំណូលមធ្យម ដែលកំពុងប្រឈមមុខនឹងបញ្ហាជាក់លាក់មួយចំនួន តាមរយៈបណ្តាញទ្វេភាគី និងពហុភាគី រួមទាំងតាមរយៈការធ្វើឲ្យប្រសើរឡើងនូវការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ និងការផ្ទេរបច្ចេកវិទ្យា លើលក្ខខណ្ឌសម្បទាន និងការអនុគ្រោះ ជាការព្រមព្រៀងគ្នាទៅវិញទៅមក សម្រាប់ការអភិវឌ្ឍ និងការពង្រឹងសមត្ថភាពរបស់ពួកគេ។

(**ខ**) បង្កើននូវប្រការដែលអាចទទួលបានរបស់បណ្តារដ្ឋ ជាពិសេសនៅតាមប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីផ្តល់ហិរញ្ញវត្ថុ បច្ចេកវិទ្យាប្រកបដោយបរិស្ថានល្អ វិទ្យាសាស្ត្រ និងរួមទាំងនវកម្ម (ការបង្កើតថ្មី) ក៏ដូចជាចំណេះដឹង និងការចែករំលែកព័ត៌មានតាមរយៈយន្តការដែលមានស្រាប់ ពោលគឺទ្វេភាគី តំបន់ និងការរៀបចំសម្រាប់កិច្ចសហការពហុភាគី រួមទាំងសហប្រជាជាតិ និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត។

(**គ**) លើកកម្ពស់ការប្រើប្រាស់ និងការពង្រីកប្រធានបទវេទិកា នៃកិច្ចសហប្រតិបត្តិការដូចជាទីកន្លែងបច្ចេកវិជ្ជាសកល និងប្រព័ន្ធសកល ដើម្បីចែករំលែក ពីការយល់ដឹង នវកម្ម (ការបង្កើតថ្មី) និងការស្រាវជ្រាវ ដើម្បីធានាថាអាចទទួលបាននូវបច្ចេកវិទ្យា និងព័ត៌មានក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

(**ឃ**) បញ្ចូលវិធានការ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ទៅក្នុងកម្មវិធីជំនួយអភិវឌ្ឍន៍ពហុភាគី និងទ្វេភាគី នៅក្នុងនិងគ្រប់វិស័យតាមការសមស្រប ដែលទាក់ទងទៅនឹងការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ការគ្រប់គ្រងធនធានធម្មជាតិបរិស្ថាន ការអភិវឌ្ឍទីក្រុង និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

## ការគាំទ្រពីអង្គការអន្តរជាតិ

៤៨. ដើម្បីគាំទ្រដល់ការអនុវត្តក្របខ័ណ្ឌនេះ ប្រការចាំបាច់មានដូចខាងក្រោម៖

(ឆ) សហប្រជាជាតិ និងអង្គការអន្តរជាតិ និងតំបន់ដទៃទៀត ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងតំបន់ និងភ្នាក់ងារម្ចាស់ជំនួយ បានចូលរួមក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ត្រូវបានស្នើសុំតាមការសមស្រប ដើម្បីពង្រឹងកិច្ចសម្របសម្រួលនៃយុទ្ធសាស្ត្ររបស់ពួកគេ។

(ខ) អង្គភាពនៃប្រព័ន្ធរបស់សហប្រជាជាតិ រួមទាំងមូលនិធិនិងកម្មវិធី និងទីភ្នាក់ងារឯកទេស តាមរយៈផែនការសកម្មភាពរបស់សហប្រជាជាតិស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយសម្រាប់ភាពធន់ ក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍របស់សហប្រជាជាតិ និងកម្មវិធីរបស់ប្រទេសដើម្បីលើកកម្ពស់ការប្រើប្រាស់ឲ្យបានប្រសើរបំផុតនៃធនធាន និងគាំទ្រដល់ប្រទេសកំពុងអភិវឌ្ឍតាមសំណើរបស់ពួកគេ ក្នុងការអនុវត្តក្របខ័ណ្ឌនេះ កិច្ចសម្របសម្រួលជាមួយនឹងក្របខ័ណ្ឌពាក់ព័ន្ធផ្សេងទៀត ដូចជាបទដ្ឋានគតិយុត្តសុខាភិបាលអន្តរជាតិ (២០០៥) រួមទាំងតាមរយៈការអភិវឌ្ឍ និងការពង្រឹងសមត្ថភាព កម្មវិធីដែលបានផ្តោត និងច្បាស់លាស់ គាំទ្រដល់អាទិភាពរបស់បណ្តារដ្ឋ ដែលមានតុល្យភាព កិច្ចសម្របសម្រួលល្អ និងមាននិរន្តរភាព នៅក្នុងអាណត្តិនីមួយៗរបស់ខ្លួន។

(គ) ការិយាល័យ សហប្រជាជាតិសម្រាប់ យុទ្ធសាស្ត្រអន្តរជាតិសម្រាប់ការកាត់បន្ថយគ្រោះមហន្តរាយ (UNISDR) ជាពិសេស បានគាំទ្រដល់ការអនុវត្ត តាមដាននិងត្រួតពិនិត្យឡើងវិញនៃក្របខ័ណ្ឌនេះតាមរយៈ៖ ការរៀបចំត្រួតពិនិត្យឡើងវិញ ពីការរីកចម្រើនតាមកាលកំណត់ ជាពិសេសសម្រាប់វេទិកាសកល តាមការសមស្រប ទាន់ពេលវេលាជាមួយនឹងដំណើរបន្តតាមដានរបស់សហប្រជាជាតិ ការគាំទ្រដល់កិច្ចអភិវឌ្ឍដែលទាក់ទងគ្នាទៅនឹងការបន្តតាមដាននៅថ្នាក់សកលនិងតំបន់ សូចនាករនិងការសម្របសម្រួលសមស្របទៅនឹងយន្តការពាក់ព័ន្ធផ្សេងទៀត សម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការប្រែប្រួលអាកាសធាតុ និងការធ្វើបច្ចុប្បន្នភាព លើគេហទំព័ររបស់ក្របខ័ណ្ឌការងារសកម្មភាពត្រួតពិនិត្យយូហ្គោ ដែលមានស្រាប់។ ការចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចការរបស់អន្តរទីភ្នាក់ងារ និងក្រុមអ្នកជំនាញ លើសូចនាករ នៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព បង្កើតឲ្យមាននូវភស្តុតាងមូលដ្ឋានគោលការណ៍ណែនាំ អនុវត្តជាក់ស្តែង សម្រាប់ការអនុវត្តនៅក្នុងកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយបណ្តារដ្ឋ និងតាមរយៈការកៀរគរអ្នកជំនាញ។ ពង្រឹងវប្បធម៌ នៃការការពារ នៅគ្រប់ភាគីពាក់ព័ន្ធ តាមរយៈការគាំទ្រដល់កិច្ចអភិវឌ្ឍ ស្តង់ដាដោយអ្នកជំនាញ និងអង្គការបច្ចេកទេស គំនិតផ្តួចផ្តើមនៃការឧបត្ថម្ភផ្នែកផ្លូវច្បាប់ និងការផ្សព្វផ្សាយពត៌មានហានិភ័យគ្រោះមហន្តរាយ គោលនយោបាយនិងការអនុវត្ត ក៏ដូចជាការផ្តល់នូវការអប់រំ និងការបណ្តុះបណ្តាល ស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ តាមរយៈអង្គការដៃគូ។ ការគាំទ្រដល់បណ្តាប្រទេសមួយចំនួន រួមទាំងតាមរយៈវេទិកាថ្នាក់ជាតិ ឬវេទិកាសមមូល របស់ពួកគេក្នុង

ការអភិវឌ្ឍផែនការជាតិរបស់ពួកគេ និន្នាការត្រួតពិនិត្យតាមដាន និងដៃគូក្នុងការងារហានិភ័យគ្រោះមហន្តរាយ ការបាត់បង់និងផលប៉ះពាល់។ កោះប្រជុំវេទិកាសកល សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការគាំទ្រដល់ការរៀបចំវេទិកាថ្នាក់តំបន់ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការថ្នាក់តំបន់។ ដឹកនាំធ្វើការពិនិត្យឡើងវិញ នៃផែនការសកម្មភាពរបស់សហប្រជាជាតិ ស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ សម្រាប់ភាពធន់។ សម្រួលដល់ការធ្វើឲ្យប្រសើរឡើង និងបន្តផ្តល់សេវាកម្ម ក្រុមប្រឹក្សាផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេស នៃសន្និសីទអន្តរជាតិស្តីពីហានិភ័យគ្រោះមហន្តរាយ ក្នុងការបំផុសចលនា នៃការងារវិទ្យាសាស្ត្រ និងបច្ចេកទេស លើការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ ដឹកនាំ ការសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយបណ្តារដ្ឋក្នុងការធ្វើបច្ចុប្បន្នភាពបច្ចេកស័ព្ទ ស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយឆ្នាំ២០០៩ ស្របជាមួយបច្ចេកស័ព្ទដែលបានព្រមព្រៀងដោយបណ្តារដ្ឋ និងរក្សាបញ្ជីឈ្មោះនៃភាគីពាក់ព័ន្ធដែលបានប្តេជ្ញាចិត្ត។

(ឃ) ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដូចជាធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍តំបន់ ពិចារណាលើអាទិភាព នៃក្របខ័ណ្ឌនេះសម្រាប់ផ្តល់នូវការគាំទ្រផ្នែកហិរញ្ញវត្ថុ និងការផ្តល់ប្រាក់កម្ចី សម្រាប់បញ្ជ្រាបការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ នៅតាមប្រទេសកំពុងអភិវឌ្ឍន៍។

(ង) អង្គការអន្តរជាតិ និងស្ថាប័នសន្ធិសញ្ញាផ្សេងទៀត រួមទាំងសន្និសីទនៃភាគីនានា ក្នុងក្របខ័ណ្ឌអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ នៅថ្នាក់សកលនិងតំបន់ និងកាកបាទក្រហមអន្តរជាតិ និងចលនាអឌ្ឍចន្ទក្រហម ដើម្បីគាំទ្រដល់ប្រទេសកំពុងអភិវឌ្ឍន៍ តាមសំណើរបស់ពួកគេ ក្នុងការអនុវត្តក្របខណ្ឌនេះ ក្នុងការសម្របសម្រួលជាមួយនឹងក្របខ័ណ្ឌពាក់ព័ន្ធផ្សេងទៀត។

(ច) កិច្ចព្រមព្រៀងផ្លូវការសកលរបស់សហប្រជាជាតិ គឺជាគំនិតផ្តួចផ្តើមដ៏សំខាន់របស់ សហប្រជាជាតិ សម្រាប់ការចូលរួមពាក់ព័ន្ធជាមួយវិស័យឯកជន និងធុរកិច្ចដើម្បីចូលរួម និងការ លើកកម្ពស់បន្ថែមទៀតនូវសារៈសំខាន់ នៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ សម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងភាពធន់។

(ឆ) សមត្ថភាពរួម នៃប្រព័ន្ធសហប្រជាជាតិ គឺដើម្បីជួយដល់ប្រទេសកំពុងអភិវឌ្ឍក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ គួរត្រូវបានពង្រឹង ដោយផ្តល់ធនធានគ្រប់គ្រាន់តាម

រយៈយន្តការនៃការផ្តល់មូលនិធិនានា រួមទាំងកំណើននៃការផ្តល់វិភាគទាន ដោយព្យាករណ៍ ស្ថេរភាព ទាន់ពេលវេលា ដល់មូលនិធិត្រាស់ (Trust Fund) របស់អង្គការសហប្រជាជាតិ សម្រាប់ការកាត់បន្ថយគ្រោះមហន្តរាយ និងលើកកម្ពស់តួនាទីរបស់មូលនិធិនេះទាក់ទងទៅនឹងការអនុវត្តក្របខ័ណ្ឌនេះ។

(ខ) សហភាពអន្តរសភា និងស្ថាប័នថ្នាក់តំបន់ពាក់ព័ន្ធដទៃទៀត និងយន្តការសម្រាប់តំណាងរាស្ត្រ តាមការសមស្របដើម្បីបន្តគាំទ្រ និងការឧបត្ថម្ភផ្នែកផ្លូវច្បាប់ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការពង្រឹងក្របខ័ណ្ឌការងារច្បាប់ជាតិ។

(ឈ) សហទីក្រុង និងអង្គការរដ្ឋាភិបាលក្នុងស្រុក និងស្ថាប័នពាក់ព័ន្ធនៃរដ្ឋាភិបាលមូលដ្ឋានដទៃទៀត បន្តគាំទ្រដល់កិច្ចសហប្រតិបត្តិការ និងការរៀនសូត្រពីគ្នាទៅវិញទៅមកក្នុងចំណោមរដ្ឋាភិបាលក្នុងស្រុក សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការអនុវត្តក្របខ័ណ្ឌនេះ។

## សកម្មភាពបន្តតាមដាន

**៤៩**. សន្និសីទអញ្ជើញមហាសន្និបាតនៅឯសម័យប្រជុំលើកទី៧០របស់ខ្លួនដើម្បីពិចារណាពីលទ្ធភាពនៃការរួមបញ្ចូលទាំងការត្រួតពិនិត្យឡើងវិញ នៃការរីកចម្រើននៅទូទាំងពិភពលោកក្នុងការអនុវត្តន៍ក្របខ័ណ្ឌ សម្រាប់ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយនេះជាផ្នែកមួយនៃដំណើរការបន្តតាមដាន ដែលបានធ្វើសមាហរណកម្ម និងសម្របសម្រួលរបស់ខ្លួនជូនទៅសន្និសីទ និងកិច្ចប្រជុំកំពូលរបស់អង្គការសហប្រជាជាតិ ស្របជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម វេទិកានយោបាយជាន់ខ្ពស់ សម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការត្រួតពិនិត្យឡើងវិញយ៉ាងទូលំទូលាយលើគោលនយោបាយ សម្រាប់រយៈពេលរៀងរាល់៤ឆ្នាំម្តង តាមការសមស្រប ដោយពិចារណាលើការចូលរួមចំណែករបស់វេទិកាសកលសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងវេទិកាថ្នាក់តំបន់សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងក្របខ័ណ្ឌការងារសកម្មភាពត្រួតពិនិត្យហ្យូហ្គោ។

**៥០**. សន្និសីទនេះ បានផ្តល់អនុសាសន៍ ជូនដល់មហាសន្និបាត ដើម្បីរៀបចំសម័យប្រជុំលើកទី៦៩ របស់ខ្លួននៃក្រុមការងារអន្តររដ្ឋាភិបាលទូលាយ រួមមានសមាសភាពនៃអ្នកជំនាញដែលជ្រើសតាំងដោយរដ្ឋជាសមាជិក និងមានការគាំទ្រដោយ ការិយាល័យសហប្រជាជាតិសម្រាប់យុទ្ធសាស្ត្រអន្តរជាតិសម្រាប់ការកាត់បន្ថយគ្រោះមហន្តរាយ (UNISDR) និងមានការ

ចូល រួមពីគ្រប់ អ្នកពាក់ព័ន្ធ សម្រាប់ការអភិវឌ្ឍនៃសំណុំសូចនាករមួយដែលអាចធ្វើបានដើម្បីវាស់ ស្ទង់ពីការរីកចម្រើននៅទូទាំងពិភពលោក ក្នុងការអនុវត្តន៍ក្របខ័ណ្ឌនេះ ដែលស្របគ្នាជាមួយ នឹងការងាររបស់ក្រុមអ្នកជំនាញអន្តរទីភ្នាក់ងារ លើសូចនាករអភិវឌ្ឍប្រកបដោយនិរន្តរភាព។សន្និសីទនេះក៏បានផ្តល់អនុសាសន៍ផងដែរថាក្រុមការងារបានចាត់ទុកអនុសាសន៍របស់ក្រុម ប្រឹក្សាវិទ្យាសាស្ត្រ និងបច្ចេកទេស ក្នុងការធ្វើបច្ចុប្បន្នភាពបច្ចេកស័ព្ទស្តីពីការកាត់បន្ថយហានិ ភ័យគ្រោះមហន្តរាយឆ្នាំ២០០៩ របស់ UNISDR ត្រូវបញ្ចប់នៅខែធ្នូឆ្នាំ២០១៦ ហើយលទ្ធផល នៃការងារនេះត្រូវបានដាក់ជូនទៅមហាសន្និបាត សម្រាប់ការពិចារណារបស់ខ្លួន និងអនុម័ត។

UNISDR

The United Nations Office for Disaster Risk Reduction

9-11 Rue de Varembé
CH 1202, Geneva
Switzerland
www.unisdr.org

រៀបចំដោយ ៖ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម)
ឧបត្ថមថវិកាដោយ ៖ អង្គការដៃគូ

NCDM